■ និទានអំពីព្រះយេស៊ូ ក្នុងជីវិតរស់នៅផ្ទាល់របស់យើង <ទំព័រ៖២

■ រដ្ឋមន្ត្រីក្រសួងសុខាភិបាល៖ គ្មានចក្ខុវិស័យផ្ទាល់ចំពោះអ្នកជំងឺបញ្ចប់ការព្យាបាលកូវីដ១៩ <ទំព័រ៖៤



កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ តុលា | ឆ្នាំ ២០២១ | លេខទី ១៤៤

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

October, 2021 | #144




■ យុវជនអាស៊ានសូមឱ្យគិតគូរបន្ថែមលើថាមពលកកើតឡើងវិញ ទំព័រ-៧

■ ផ្សោតទន្លេមេគង្គ អន្លង់ឈើទាល–ព្រំដែនកម្ពុជានិងឡាវ កំពុងបាត់បង់ទាំងស្រុង ទំព័រ-១០&១១



# និទានអំពីព្រះយេស៊ូ ក្នុងជីវិតរស់នៅផ្ទាល់របស់យើង



បងប្អូនជាទីរាប់អាន! តាមជំនឿរបស់គ្រីស្តបរិស័ទ បានដឹងខ្លួនយ៉ាងច្បាស់ថា ព្រះជាម្ចាស់ បានត្រាស់ហៅម្នាក់ៗ តាមឈ្មោះរៀងៗខ្លួន ដើម្បី ទទួលសេចក្តីស្រឡាញ់ ទទួលជីវិតថ្មី ក្នុងអង្គព្រះគ្រីស្តតាមរយៈអគ្គសញ្ញាជ្រមុជទឹក។

«ព្រះបន្ទូលបានកើតមកជាមនុស្ស ហើយគង់នៅកណ្តាលចំណោម យើងរាល់គ្នា យើងបានឃើញសិរីរុងរឿងរបស់ព្រះអង្គ ជាសិរីរុងរឿងនៃព្រះបុត្រា តែមួយគត់ ដែលមកពីព្រះបិតា ព្រះអង្គពោរពេញដោយព្រះហឫទ័យ ប្រណីសន្តោស និងសេចក្តីពិត»។ (យ៉ូហាន ១,១៤)

តើខ្ញុំនឹងនិទានអំពីព្រះយេស៊ូយ៉ាងដូចម្តេច? និងនិទានអំពីសេចក្តីពិត និងអំពីព្រះហឫទ័យប្រណីសន្តោសរបស់បុត្រមនុស្សយ៉ាងដូចម្តេច?

ក្នុងរដូវកាលនៃការឆ្លងរីករាលដាលនៃវីរុសកូវីដ១៩ដ៏សាហាវ ទាំងបងប្អូនទាំងយើងខ្ញុំទាំងអស់គ្នា ភ័យខ្លាច និងខិតខំទូលអង្វររកព្រះជាម្ចាស់។ ពេលខ្លះមានសំណួរចោទថា តើព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្តោសចំពោះបុត្រធីតារបស់ព្រះអង្គយ៉ាងណាខ្លះ? តើព្រះយេស៊ូ ពិតជាគង់នៅកណ្តាលចំណោមយើងដែរមែនឬទេ?

ឈប់ត្រង់នេះបន្តិច ហើយស្ងឹងស្ងាធ អធិដ្ឋាន យើងប្រាកដជាជឿច្បាស់ថា បុត្រមនុស្សគង់នៅជាមួយ និងកណ្តាលចំណោមយើងពិតមែន។ ព្រោះម្នាក់ៗថា គ្រីស្តបរិស័ទគ្រប់រូប ទទួលព្រះវិញ្ញាណតែមួយ និងជីវិតថ្មីក្នុងអង្គព្រះគ្រីស្តតែមួយ។ យើងបានទទួលព្រះគ្រីស្តចូលក្នុងរូបកាយរបស់ខ្លួនម្តងជាសូរេចទៅហើយ។

ត្រង់ចំណុចនេះនាំឱ្យយើងទាំងអស់គ្នាភ្ញាក់ស្មារតី ហើយគិតថា ពិតជាអស្ចារ្យមែន និង មានអារម្មណ៍រំភើបពិតមែន ដូចសាវ័ក ពីររូប ធ្វើដំណើរទៅភូមអេម៉ាអ៊ូ។ (លូកា ២៩៣២)

បងប្អូនជាទីស្រឡាញ់!

ព្រះសហគមន៍នៅប្រទេសកម្ពុជាយើង មានវ័យក្មេងខ្ចីណាស់ ហើយយើងបានទទួលជំនឿ តាមរយៈសាសនទូតនានា ដែលបានមកបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជា។ អស់លោក បព្វជិត បព្វជិតា និងបងប្អូនទាំងនោះ បានចែករំលែកការរស់នៅផ្ទាល់ខ្លួន ជីវិតផ្ទាល់ ដើម្បីបង្ហាញអំពីវត្តមានរបស់ព្រះយេស៊ូ ឱ្យបងប្អូនបានមើលឃើញនូវសេចក្តីស្រឡាញ់ ទទួលបានសេចក្តីសង្ឃឹម និងអំណរសប្បាយផងដែរ។

តើខ្ញុំនឹងចូលរួមចែករំលែក និទានអំពីព្រះយេស៊ូក្នុងជីវិតរស់នៅរបស់ខ្លួនយ៉ាងដូចម្តេច? បងប្អូនមិនចាំបាច់ឆ្លើយភ្លាមៗនោះទេ តែសូមពិនិត្យអំពីដំណើរជីវិតរបស់ខ្លួនឡើងវិញ អ្វីខ្លះដែលយើងបានទទួល ជាអំណោយទានដែលមកពីព្រះជាម្ចាស់ ហើយត្រូវចែករំលែកដល់បងប្អូនឯទៀតៗនោះ។

ក្នុងខែតុលានេះ ព្រះសហគមន៍បើកសន្និបាត សាកល ដើម្បីជួយគ្រីស្តបរិស័ទរិះគិតឡើងវិញ អំពីការធ្វើដំណើរជាមួយគ្នា ជាផ្លូវតែមួយ ចូលរួមប្រកាសដំណឹងល្អ។

ដូច្នេះសរុបមក គ្រីស្តបរិស័ទមានតួនាទីយ៉ាងសំខាន់ ក្នុងការនិទាន អំពីព្រះយេស៊ូគ្រីស្ត ក្នុងជីវិតផ្ទាល់ខ្លួន។ សូមពិចារណា តើចូលរួមបែបណា ក្នុងនាំដំណឹងល្អដល់ជនក្រីក្រ? នាំឱ្យបងប្អូនចូលរួមជាមួយគ្នាបែបណា? ធ្វើដូចម្តេចដើម្បីរួមដំណើរជាមួយគ្នា ជាផ្លូវតែមួយ? ក្នុងគ្រាដែលយើង មានវ័យខុសគ្នា ធនធានខុសគ្នា សភាពជីវិតខុសគ្នា ចំណេះដឹងខុសគ្នា និងមានជាតិសាសន៍ខុសគ្នា ដើម្បីនាំដំណឹងអំពីការសង្គ្រោះសម្រាប់បងប្អូនយើងដទៃទៀតនោះ៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# កម្ពុជាក្លាយជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន នៅឆ្នាំ២០២២




*អត្ថបទ៖ អមរិន្ទ ដានុត*

ការប្រជុំលើកទី៣៨និងលើកទី៣៩ត្រូវបានបិទបញ្ចប់ជាមួយនឹងការទទួលជាប្រធានប្ដូរវេនអាស៊ានរបស់កម្ពុជាសម្រាប់ឆ្នាំ២០២។ នេះជាការលើកឡើងរបស់សម្ដេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នារសៀលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១នេះ។

សម្ដេចតេជោ ហ៊ុន សែន បានលើកឡើងថា៖ «ខ្ញុំជានាយករដ្ឋមន្ត្រីកម្ពុជាមួយរូបដែលបានកាន់ញញួរប្រធានអាស៊ានរហូត៣ដង។ ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណចំពោះបងប្អូនជនរួមជាតិដែលបានគាំទ្រដល់រូបខ្ញុំក្នុងការដឹកនាំកម្ពុជាដែលធ្វើឱ្យខ្ញុំមានលទ្ធភាពចូលរួមក្នុងកិច្ចការតំបន់និងអន្តរជាតិតាមរយៈអាស៊ាន»។

នៅក្នុងពិធីប្រគល់តំណែងប្រធានអាស៊ានជូនកម្ពុជា នៅថ្ងៃដដែលនេះ សម្ដេចតេជោ ហ៊ុន សែន បានលើកឡើងថា សម្ដេចពិតជាមានមោទនភាពយ៉ាងក្រៃលែង ដែលកម្ពុជាបានទទួលតំណែងជាប្រធានប្ដូរវេនរបស់អាស៊ានសម្រាប់ឆ្នាំ ២០២២ ដោយសម្ដេចបានឆ្លៀតឱកាសនេះ វាយតម្លៃខ្ពស់ចំពោះព្រុយណេដែលបានដឹកនាំអាស៊ានក្នុងឆ្នាំ ២០២១ ក្រោមមូលបទ «យើងយកចិត្តទុកដាក់, យើងត្រៀមលក្ខណៈ, យើងរីកចម្រើន»។

សម្ដេចនាយករដ្ឋមន្ត្រីក៏បានកោតសរសើរជូនព្រះចៅស៊ុលតង់ ហាជី ហាសាណាល់ប៊ុលគីយ៉ា (Sultan Haji Hassanal Bolkiah) ចំពោះភាពជាអ្នកដឹកនាំ ប្រកបដោយឆ្លាតវៃ និងប្រសិទ្ធភាព និងសម្រេចបាននូវសមិទ្ធផលប្រកបដោយផ្លែផ្កាជាច្រើន រួមទាំងជោគជ័យ នៃកិច្ចប្រជុំកំពូលដែលទើបតែបញ្ចប់ ។

សម្ដេចបានមានប្រសាសន៍ថា ៖ «ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២, កម្ពុជានឹងដឹកនាំកិច្ចខិតខំប្រឹងប្រែងរួមរបស់អាស៊ានដើម្បី ឈានទៅសម្រេចបាននូវសមិទ្ធផលសំខាន់ៗថែមទៀត ជាពិសេសជំរុញសម្ទុះនៃដំណើរការកសាងសហគមន៍ អាស៊ានប្រកបដោយសមធម៌, រឹងមាំ និងបរិយាបន្ន ស្របតាមស្មារតីស្នូលរបស់អាស៊ាន គឺចក្ខុវិស័យមួយ, អត្តសញ្ញាណមួយ និងសហគមន៍មួយ»។

សម្ដេចនាយករដ្ឋមន្ត្រីបានរំលេខនូវអាទិភាពការងារមួយចំនួនសម្រាប់ឆ្នាំ ២០២២ មាន សសរស្ដម្ភនយោបាយនិងសន្តិសុខ, សសរស្ដម្ភសេដ្ឋកិច្ច និងសសរស្ដម្ភសង្គម-វប្បធម៌។

សម្រាប់សសរស្ដម្ភនយោបាយ និងសន្តិសុខ៖ កម្ពុជានឹងយកចិត្តទុកដាក់ពង្រឹងមជ្ឈភាពអាស៊ាន និង ឯកភាពអាស៊ាន, ទាំងក្នុងយន្តការតំបន់ និងទាំងកិច្ចសហប្រតិបត្តិការជាមួយដៃគូខាងក្រៅ, ដោយឈរលើ មាគ៌ា និង គោលការណ៍របស់អាស៊ាន ដូចមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន, សន្ធិសញ្ញាមិត្តភាព និង កិច្ច

សន្ទរកថារបស់ សម្ដេចតេជោ ហ៊ុន សែន ក្នុងពិធីប្រគល់តំណែងប្រធានអាស៊ានជូនកម្ពុជាថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០២។ សហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ និងទស្សនវិស័យអាស៊ានស្ដីពីឥណ្ឌូប៉ាស៊ីហ្វិក ។ អាស៊ានក៏ត្រូវមានភាពធន់ និងរឹងមាំ ទប់ទល់បានពីសម្ពាធ និងឥទ្ធិពលនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយដែលកំពុងតែ កើនឡើង, បញ្ហាឧក្រិដ្ឋកម្មឆ្លងដែន, ភេរវកម្ម, ការប្រែប្រួលអាកាសធាតុ និង ជំងឺរាតត្បាត ។ល។ ដើម្បីធានា ដំណើរទៅមុខ ក្នុងសន្តិភាព, សន្តិសុខ និងវិបុលភាព ។

ចំណែក សសរស្ដម្ភសេដ្ឋកិច្ច៖ កម្ពុជានឹងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ នូវរាល់គំនិតផ្ដួចផ្ដើម និង វិធានការ ដែលបានឯកភាពគ្នា និង ទាញយកផលប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី នានា ដើម្បីស្ដារកំណើនសេដ្ឋកិច្ចឱ្យបានឆាប់ ក្នុងពេលដែលយើងរស់ជាមួយនឹងកូវីដ-១៩ ក្នុងប្រក្រតីភាព ថ្មី និងធានាឱ្យអាស៊ាននៅតែជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និង ការវិនិយោគ ប្រកបដោយភាពទាក់ទាញ និង ជីវភាព ពិសេសតាមរយៈការជំរុញការតភ្ជាប់ទាំងរូបវន្ត និងឌីជីថល ការលើកកម្ពស់សមត្ថភាពរបស់សហគ្រាស ខ្នាតមីក្រូ, តូច និងមធ្យម (MSMEs) និងការលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី និង យុវជន ព្រមទាំង ការងារអាទិភាពផ្សេងទៀត ដើម្បីកាត់បន្ថយគម្លាតអភិវឌ្ឍន៍ និងពង្រឹងសមាហរណកម្មតំបន់។

រីឯ សសរស្ដម្ភសង្គម-វប្បធម៌៖ កម្ពុជានឹងជំរុញការអភិវឌ្ឍធនធានមនុស្សឱ្យឆ្លើយតបនឹងតម្រូវការ ជាក់ស្ដែងក្នុងការកសាងសហគមន៍ រួមទាំងជំរុញការចូលរួមរបស់ស្ត្រី និង យុវជន នៅក្នុងការរក្សា និង ក សាងសន្តិភាព និង ការអភិវឌ្ឍប្រព័ន្ធការពារសង្គមប្រកបដោយបរិយាប័ន្នផងដែរ ។ អាទិភាពសំខាន់មួយ ទៀតគឺការជំរុញនូវការប្រាស្រ័យទាក់ទងរវាងប្រជាជន និង ប្រជាជន សំដៅពង្រឹងស្មាតីអត្តសញ្ញាណអាស៊ាន តែមួយ ។

សម្ដេចតេជោបានបញ្ជាក់ថា កម្ពុជានឹងបន្តកៀរគរការគាំទ្រ និងកិច្ចសហប្រតិបត្តិការ ដើម្បីសម្រេចគោលដៅនៃការកសាង សហគមន៍អាស៊ានទាំងបី តាមទស្សនវិស័យសហគមន៍អាស៊ានឆ្នាំ ២០២៥ ។ ជាមួយគ្នានេះ លោកក៏នឹងជំរុញផងដែរ នូវដំណើរការរៀបចំ ទស្សនវិស័យសហគមន៍អាស៊ានសម្រាប់រយៈពេលក្រោយឆ្នាំ ២០២៥ ។

សម្ដេចបានមានប្រសាសន៍ថា ៖ «ក្នុងនាមជាប្រធានអាស៊ានឆ្នាំ ២០២២ កម្ពុជាប្ដេជ្ញាចិត្តដឹកនាំអាស៊ានបោះជំហានទៅមុខក្រោមមូលបទ «អាស៊ានរួមគ្នាធ្វើ - ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា (ASEAN A.C.T.: Address-ing_ Challenges Together)» ដើម្បីភាពសុខដុមរមនា, សន្តិភាព និង វិបុលភាពក្នុងតំបន់ទាំងមូល។ ខ្ញុំទន្ទឹងរង់ចាំស្វាគមន៍ថ្នាក់ដឹកនាំទាំងអស់យ៉ាងកក់ក្ដៅ នៅកម្ពុជាឆ្នាំ២០២២»៕

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល៖ គ្មានចត្តាឡីស័ក ចំពោះអ្នកជំងឺបញ្ចប់ការព្យាបាលកូវីដ១៩

*អត្ថបទ៖ អមរិន្ទ ដានុត*

រដ្ឋមន្ត្រីក្រសួងសុខាភិបាល លោក ម៉ម ប៊ុនហេង បានសម្រេចលើកលែងកាតព្វកិច្ចធ្វើចត្តាឡីស័ក ចំពោះអ្នកជំងឺកូវីដ-១៩ ដែលបានបញ្ចប់ការព្យាបាល នៅតាមមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ និងអ្នកជំងឺកូវីដ-១៩ សម្រាកថែទាំ និងព្យាបាលនៅតាមផ្ទះ។

លោក ម៉ម ប៊ុនហេង បានលើកឡើងតាមរយៈលិខិតផ្ញើជូនគ្រប់ប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្តទាំងអស់ពីការលើកលែងកាតព្វកិច្ចធ្វើចត្តាឡីស័កនេះ ដោយលោកបានបញ្ជាក់ថា គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ធ្វើការលើកលែងកាតព្វកិច្ចធ្វើចត្តាឡីស័កចំពោះអ្នកជំងឺកូវីដ-១៩ ដែលបានបញ្ចប់ការព្យាបាល។

លោកថា ៖ «អ្នកជំងឺកូវីដ-១៩ ដែលបានបញ្ចប់ការព្យាបាលនៅតាមមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ពុំតម្រូវឱ្យធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ទៀតទេ ហើយអ្នកជំងឺកូវីដ-១៩ សម្រាកថែទាំ និងព្យាបាលនៅតាមផ្ទះត្រូវបានអនុញ្ញាតឱ្យបញ្ចប់ការព្យាបាលទៅតាមលក្ខខណ្ឌមួយចំនួនផងដែរ»។

លោកថា លក្ខខណ្ឌទាំងនោះមានដូចជាករណីអ្នកជំងឺកូវីដ-១៩ ពុំបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ អនុញ្ញាតឱ្យបញ្ចប់ការព្យាបាលនៅថ្ងៃទី១៤ ប្រសិនបើពុំមានរោគសញ្ញាជំងឺកូដ-១៩ រយៈពេល ៣ថ្ងៃចុងក្រោយបន្តបន្ទាប់គ្នា (ថ្ងៃទី១១ ១២ និង១៣) និងពុំតម្រូវឱ្យធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ទៀតទេ។

រដ្ឋមន្ត្រីរូបនេះបានបន្តថា ករណីអ្នកជំងឺកូវីដ-១៩ បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន បានពេញលេញ ហើយចាប់ពីថ្ងៃទី៦ ទៅពុំមានរោគសញ្ញាជំងឺកូវីដ-១៩ រយៈពេល ៣ថ្ងៃ បន្តបន្ទាប់គ្នា (ថ្ងៃទី៦ ៧ និង៨) ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយខ្លួនឯង នៅថ្ងៃទី។ ប្រសិនបើទទួលបានលទ្ធផលតេស្តកូវីដ-១៩ អវិជ្ជមាន [Ag (-)] អនុញ្ញាតឱ្យបញ្ចប់ការព្យាបាល និងពុំតម្រូវឱ្យធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ទៀតទេ។

លោក ម៉ម ប៊ុនហេង ថា ៖ «ប្រសិនបើលទ្ធផលតេស្តកូវីដ-១៩ វិជ្ជមាន [Ag (+) ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយខ្លួនឯងឡើងវិញនៅ ២ថ្ងៃបន្ទាប់ ( ថ្ងៃ ទី ១ ១) ហើយអនុញ្ញាតឱ្យបញ្ចប់ការព្យាបាល ប្រសិនបើទទួលបានលទ្ធផលតេស្តកូវីដ-១៩ អវិជ្ជមាន [Ag (-)] និងពុំតម្រូវឱ្យធ្វើចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ ទៀតទេ»។

លោកបានបញ្ជាក់បន្ថែមថា ក្នុងករណីពុំមានលទ្ធភាពធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយខ្លួនឯង នៅថ្ងៃទី៩ អនុញ្ញាតឱ្យបញ្ចប់ការព្យាបាលនៅថ្ងៃទី១២ ប្រសិនបើពុំមានរោគសញ្ញាជំងឺកូវីដ-១៩ ចាប់ពីថ្ងៃទី៩ ទៅរយៈពេល ៣ថ្ងៃបន្តបន្ទាប់គ្នា ( ថ្ងៃទី៩ ១០ និង១១) និងពុំតម្រូវឱ្យធ្វើចត្តាឡីស័ក រយៈពេល១៤ថ្ងៃ ទៀតទេ។

លក្ខខណ្ឌចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ចំពោះអ្នកជំងឺកូវីដ-១៩ ដែលបានបញ្ចប់ការព្យាបាល នៅតាមមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ និងអ្នកជំងឺកូវីដ-១៩ សម្រាកថែទាំ និងព្យាបាលនៅតាមផ្ទះ ដែលបាន ដាក់ឱ្យប្រើប្រាស់នាពេលកន្លងមក ត្រូវទុកជានិរាករណ៍។

លោក ម៉ម ប៊ុនហេង បានឱ្យដឹងទៀតថា អ្នកជំងឺកូវីដ-១៩ ដែលត្រូវបានអនុញ្ញាតឱ្យបញ្ចប់ការព្យាបាល ទោះបីត្រូវបានលើកលែងកាតព្វកិច្ចចត្តាឡីស័ក ប៉ុន្តែត្រូវតែបន្តអនុវត្តវិធានការសុខាភិបាលជាធរមាន ដោយចូលរួមអនុវត្តឱ្យបាននូវវិធានការ ៣កុំ ការពារ ឱ្យបានខ្ជាប់ខ្ជួន។

ជាមួយគ្នានេះដែរ ក្រសួងសុខាភិបាល ក៏បានសម្រេចលើកលែងការធ្វើចត្តាឡីស័ក ចំពោះក្រុមគ្រូពេទ្យ និងក្រុមអ្នកផ្តល់សេវាជួរមុខ ដែលអនុវត្តបានខ្ជាប់ខ្ជួនវិធានការសុខាភិបាល និងធ្វើតេស្តកូវីដអវិជ្ជមាន PCR។

លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីសុខាភិបាល បានឲ្យដឹងថា យោងតាមចំណារឯកភាពរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១ លើសំណើសុំគោលការណ៍ របស់គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ដោយផ្អែកលើមូលដ្ឋានសំខាន់ចំនួន២ គឺ ការធ្វើចត្តាឡីស័ករបស់អ្នកជំងឺកូវីដ-១៩ ដែលបានជាសះស្បើយ ត្រូវបានលុបចោល និង អត្រាក្រុមគ្រូពេទ្យ និងក្រុមផ្តល់សេវាជួរមុខដែល បានចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងដូសមូលដ្ឋាន និងដុសជំរុញ មានកម្រិតខ្ពស់ ដែលនាំឲ្យមានភាពស៊ាំ និងប្រសិទ្ធភាព ក្នុងការកាត់បន្ថយកម្រិតគ្រោះថ្នាក់នៃវីរុសកូវីដ-១៩ គណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងសូមធ្វើបច្ចុប្បន្នភាពរបបធ្វើចត្តាឡីស័ករបស់ក្រុមគ្រូពេទ្យ និងក្រុមផ្តល់សេវាជួរមុខ នៅតាមមន្ទីរពេទ្យ និងមណ្ឌលព្យាបាលជំងឺកូវីដ-១៩៕

# កម្ពុជាសម្រេចការចាក់វ៉ាក់សាំងកូវីដ-១៩បានដល់ ១០លាននាក់ និងបានប្រកាសបើកប្រទេសឡើងវិញ

*អត្ថបទ៖ អមរិន្ទ ដានុត*

នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០២១ កម្ពុជាបានចាក់វ៉ាក់សាំងការពារកូវីដ-១៩ បានចំនួន១០លាន៨៨នាក់ ដែលស្មើនឹងជាង១០០% នៃប្រជាពលរដ្ឋ១០លាននាក់ដែលត្រូវចាក់វ៉ាក់សាំង។ នេះជាជោគជ័យធំធេងណាស់នៅក្នុងក្របខ័ណ្ឌនៃខឿនការពារសុខភាពរបស់ប្រជាជនកម្ពុជា។ នេះជាការលើកឡើងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។

សម្តេចបានលើកឡើងថា ៖ «ទោះបីយើងចាក់វ៉ាក់សាំងបានជាង១០លាននាក់ស្មើនឹងជាង ១០០%នៃចំនួនគ្រោងដំបូងក៏ដោយ ក៏យើងនៅមានប្រជាជនរាប់ម៉ឺននាក់ទៀតដែលមិនទាន់បានចាក់វ៉ាក់សាំងដែលយើងត្រូវបន្តចាក់វ៉ាក់សាំងជូនឱ្យបានគ្រប់ៗគ្នា»។

ក្រៅពីប្រជាជនដែលមានអាយុ១៨ឡើងចំនួនជាង ១០លាននាក់បានចាក់វ៉ាក់សាំង កម្ពុជាក៏បានចាក់វ៉ាក់សាំងជូនកុមារ និងយុវវ័យអាយុ១២ទៅ១៨ឆ្នាំ និងកុមារអាយុពី៦ដល់១២ផងដែរ។

ជាមួយគ្នានេះដែរ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០២១ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានប្រកាសបើកប្រទេសឡើងវិញគ្រប់វិស័យផងដែរ ស្របពេលដែលគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនបានបើកដំណើរការឡើងវិញផងដែរ។

កម្ពុជាក៏បានប្រកាសបិទយុទ្ធនាការចាក់វ៉ាក់សាំងដល់ពលរដ្ឋដែលមានអាយុចាប់ពី០៦ឆ្នាំឡើងជុំទី១ក្នុងក្របខណ្ឌទូទាំងប្រទេសផងដែរ ហើយក៏បានប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ដល់កុមារអាយុ០៥ឆ្នាំ ដែលមានចំនួនប្រមាណជាង៣០ម៉ឺននាក់បន្តទៀតផងដែរ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងនូវកត្តាចំនួន៤ដែលលោកគិតថាកម្ពុជាអាចបើកប្រទេសឡើងវិញបាន ក្នុងនោះ មានការសម្រេចបានលទ្ធផលនៃការចាក់វ៉ាក់សាំងកូវីដ១៩, រាជរដ្ឋាភិបាលបានពង្រឹងនិងពង្រីកសមត្ថភាពក្នុងការព្យាបាលជំងឺកូវីដ, ឆ្លងកាត់បទពិសោធន៍នៃការគ្រប់គ្រង ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងរបៀបគ្រប់គ្រងទប់ស្កាត់នៃជំងឺនេះក្នុងទ្រង់ទ្រាយធំ និងការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការការពារខ្លួន និងការព្យាបាលជំងឺកូវីដ១៩ ។

ទន្ទឹមនឹងនេះដែរ ទោះបីជាប្រទេសត្រូវបានបើកដំណើរការឡើងវិញក៏ដោយ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានអំពាវនាវជនរួមជាតិទាំងអស់បន្តអនុវត្តវិធានការការពារតាមការណែនាំរបស់ក្រសួងសុខាភិបាលពិសេស វិធានការ ៣ការពារ និង៣កុំ ។

សម្តេចបានមានប្រសាសន៍ថា ៖ «ដោយសារវ៉ាក់សាំងកូវីដ១៩ តែមួយមុខបើទោះបីចាក់បានប៉ុន្មានដូសរហូតមុជវ៉ាក់សាំងក៏មិនអាចការពារបានដែរ ប្រសិនជាបងប្អូននៅតែធ្វេសប្រហែសបោះបង់ចោលវិធីការពារខ្លួនតាមរយៈវិធានការ ៣ការពារនិង៣កុំ»។

គួរបញ្ជាក់ផងដែរថា អ្នកដែលមានលេខរៀងទី១០លាននាក់ គឺបានទៅលើ អ្នកស្រី សុខ ផាត់ អាយុ៨៩ឆ្នាំរស់នៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប៕



# កម្ពុជាមានទូរប្រព័ន្ធត្រជាក់សម្រាប់រក្សាវ៉ាក់សាំងកូវីដ១៩ នៅសីតុណ្ហភាព-៧០ ទៅ-៨០អង្សាសេ

*អត្ថបទ៖ អមរិន្ទ ដានុត*

បរិក្ខារប្រព័ន្ធត្រជាក់ខ្លាំងចំនួន៩គ្រឿងដែលមានតម្លៃជិត ៦០.០០០ដុល្លារ ដែលអង្គការយូនីសេហ្វទទួលពីយន្តការកូវ៉ាក់ ដើម្បីជួយពង្រឹកសមត្ថភាពកម្ពុជាក្នុងការផ្តល់វ៉ាក់សាំងប្រកបដោយសុវត្ថិភាពត្រូវបានផ្តល់ដល់ក្រសួងសុខាភិបាលកាលពីដើមខែវិច្ឆិកាកន្លងមកនេះ។

សេចក្តីប្រកាសរបស់អង្គការយូនីសេហ្វបានឱ្យដឹងថា គ្រឿងបរិក្ខារទាំងនេះបានទទួលពីយន្តការកូវ៉ាក់ និងក្រោមកម្មវិធីហិរញ្ញប្បទានផ្គត់ផ្គង់សម្ភាររបស់ខ្លួន ដែលយូនីសេហ្វកំពុងផ្តល់ការគាំទ្របច្ចេកទេសដល់បណ្តារដ្ឋាភិបាលនានា និងការសម្របសម្រួលធ្វើលទ្ធកម្ម និងភស្តុភារដើម្បីធានានូវការមកដល់របស់បរិក្ខារទាំងនេះប្រកបដោយសុវត្ថិភាព។

បរិក្ខារទាំងនេះរួមមាន ទូប្រព័ន្ធត្រជាក់ដែលមានសីតុណ្ហភាពទាបខ្លាំង (ULT) ចំនួន៩គ្រឿង ឧបករណ៍រក្សាលំនឹងចរន្តអគ្គិសនីចំនួន៩គ្រឿង និងគ្រឿងបន្លាស់ទាំងអស់ ដែលចាំបាច់ដើម្បីការថែទាំទូប្រព័ន្ធត្រជាក់ ULT សម្រាប់រយៈពេលវែង។

លោកស្រី Foroogh Foyouzat តំណាងអង្គការយូនីសេហ្វ (UNICEF) ប្រចាំកម្ពុជា បានថ្លែងថា ទូប្រព័ន្ធត្រជាក់ទាំងអស់នេះរួមបញ្ចូលគ្នាអាចរក្សាទុកវ៉ាក់សាំងបានចំនួន ២,៤លានដូស។ ទូប្រព័ន្ធត្រជាក់ខ្លាំងបំផុត គឺចាំបាច់សម្រាប់វ៉ាក់សាំង ដែលត្រូវតែរក្សាទុកនៅសីតុណ្ហភាពដក ៧០ ទៅដក ៨០អង្សារសេ ដូចជាវ៉ាក់សាំងប្រើប្រាស់បច្ចេកវិទ្យា Messenger RNA (mRNA)។

លោកស្រី មានប្រសាសន៍ថា ៖ «ការមកដល់នៃបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំងទាំងនេះ គឺជាផ្នែកមួយនៃសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលក្នុងបង្កើតសមត្ថភាពបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំង នៅក្នុងសេវាសុខភាពសាធារណៈជាលើកដំបូង»។

តំណាងអង្គការយូនីសេហ្វរូបនេះបានបន្ថែមថា ការបង្កើតសមត្ថភាពបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំង ជួយកម្ពុជាក្នុងការធ្វើពិពិធភាពវ៉ាក់សាំងកូវីដ-១៩ បន្ថែមទៀត ដើម្បីបញ្ចូលវ៉ាក់សាំងប្រភេទ mRNA។ បរិក្ខារប្រព័ន្ធត្រជាក់ខ្លាំង ក៏អាចត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រសកម្មភាពមន្ទីរពិសោធន៍ និងសកម្មភាពស្រាវជ្រាវ និងអាចពង្រឹកសមត្ថភាពរបស់មជ្ឈមណ្ឌលផ្តល់ និងរក្សាទុកឈាមបានផងដែរ។

បើតាមអង្គការនេះ ការមានបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំង នឹងផ្តល់លទ្ធភាពប្រើប្រាស់លើសពីការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត គឺដើម្បីធ្វើឲ្យការផ្តល់វ៉ាក់សាំងជាប្រចាំទូទៅ កាន់តែមានលក្ខណៈងាយស្រួល សម្រាប់ប្រជាជនកម្ពុជា។

ការផ្តល់នូវបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំងទាំងប្រាំបួនគ្រឿងមកដល់កម្ពុជា គឺជាផ្នែកមួយនៃគោលដៅសកលរបស់យូនីសេហ្វ ក្នុងការផ្តល់ទូប្រព័ន្ធត្រជាក់ដែលមានសីតុណ្ហភាពទាបខ្លាំង ចំនួន ៣៥០គ្រឿងទៅដល់ប្រទេសជាង ៤៥ ជំនួសមុខឲ្យយន្តការកូវ៉ាក់។

នៅកម្ពុជា យូនីសេហ្វ គឺជាដៃគូចម្បងក្នុងការផ្តល់ការគាំទ្របច្ចេកទេសដល់រាជរដ្ឋាភិបាលលើយុទ្ធសាស្ត្រ និងការត្រៀមខ្លួនលើបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំង ហើយការមកដល់នៃបរិក្ខារនៅថ្ងៃនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរួមនេះប៉ុណ្ណោះ។




យូនីសេហ្វ នឹងបន្តគាំទ្រកម្មវិធីផ្តល់ថ្នាំបង្ការរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការរៀបចំផែនការ និងការរៀបចំយុទ្ធសាស្ត្រ ការគ្រប់គ្រងវ៉ាក់សាំង និងការបង្កើតតម្រូវការថ្នាំបង្ការ ការកសាងសមត្ថភាព និងការតាមដានត្រួតពិនិត្យ ដើម្បីធានានូវការបំពេញទៅតាមបទដ្ឋាននៃបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំង។

បរិក្ខារប្រព័ន្ធត្រជាក់ខ្លាំងបន្ថែមទៀត នឹងត្រូវផ្តល់ជូននៅក្នុងខែខាងមុខជាបន្តបន្ទាប់ ដែលជាផ្នែកមួយនៃការបន្តពង្រឹងបរិក្ខារប្រព័ន្ធត្រជាក់ខ្លាំងនៅកម្ពុជា។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាលនិងជាប្រធានគណៈកម្មការបំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ១៩ក្នុងក្របខណ្ឌទូទាំងប្រទេស ក៏បានថ្លែងក្នុងពិធីប្រគល់និងទទួលនូវទូប្រព័ន្ធត្រជាក់នេះថា ការទទួលបាននូវទូប្រព័ន្ធត្រជាក់នេះ គឺជាអត្ថប្រយោជន៍មួយទៀតសម្រាប់ប្រទេសកម្ពុជា ដែលត្រូវតែត្រៀមលក្ខណៈឱ្យបានរួចរាល់ ដោយសារនៅពេលឆាប់ៗខាងមុខនេះ កម្ពុជាអាចនឹងទទួលបានវ៉ាក់សាំងផ្សេងៗទៀតពីមជ្ឈមណ្ឌលកូវ៉ាក់ផងនិងប្រហែលអាចទទួលពីប្រទេសដៃគូទ្វេភាគីផងដែរ។

លោកស្រីបានបញ្ជាក់ថា ៖ «ថ្ងៃនេះជាការវិវត្តថ្មីមួយទៀតសម្រាប់ការចាក់វ៉ាក់សាំងរបស់យើង ហើយខ្ញុំសង្ឃឹមថាប្រព័ន្ធត្រជាក់ទាំង៩គ្រឿងនេះ នឹងផ្តល់អត្ថប្រយោជន៍ក្នុងការចាក់វ៉ាក់សាំងនាពេលអនាគតខាងមុខនេះ»។

គួរបញ្ជាក់ថា យន្តការកូវ៉ាក់ គឺជាសម្ព័ន្ធភាពសកលក្រោមកិច្ចដឹកនាំរបស់ សម្ព័ន្ធសកលសម្រាប់វ៉ាក់សាំង និងថ្នាំបង្ការ (GAVI) សម្ព័ន្ធនវានុវត្តន៍ដើម្បីត្រៀមទប់ទល់នឹងការរាតត្បាតនៃជំងឺ (CEPI) អង្គការសុខភាពពិភពលោក និងយូនីសេហ្វ ដើម្បីធានាការទទួលបានវ៉ាក់សាំងប្រកបដោយសមធម៌នៅតាមប្រទេសកំពុងអភិវឌ្ឍ៕







# របាយការណ៍ថ្មី រំលេចពីផលប៉ះពាល់នៃសកម្មភាពរបស់មនុស្ស និងផ្នែកបរិស្ថានក្នុងអាងទន្លេមេគង្គក្រោម





*អត្ថបទ៖ អមរិន្ទ ដានុត*

គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) កាលពីខែតុលាកន្លងមក បានបង្ហាញថា ការនេសាទនៅតែជារបរចិញ្ចឹមជីវិតដ៏សំខាន់ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ក៏ប៉ុន្តែការនេសាទហួសកម្រិត និងការខូចខាតទីជម្រកបណ្តាលមកពីកំណើនប្រជាជនយ៉ាងសន្ធឹកសន្ធាប់ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការប្រែប្រួលអាកាសធាតុ កំពុងដាក់សម្ពាធយ៉ាងខ្លាំងលើជលផលអាងទន្លេមេគង្គក្រោម ស្របពេលដែលបម្រែបម្រួលនៃប្រព័ន្ធអេកូឡូស៊ីក្នុងអាងនេះ កំពុងជះឥទ្ធិពលលើស្ថានភាពសង្គម។

របាយការណ៍ចំនួនពីរក្រោមចំណងជើង «ស្ថានភាព និងនិន្នាការនៃភាពសម្បូរបែប និងភាពចម្រុះ នៃមច្ឆាក្នុងអាងទន្លេមេគង្គក្រោម ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៨» (ហៅកាត់ថា FADM) និង «ការតាមដានផលប៉ះពាល់សង្គម និងការវាយតម្លៃភាពងាយរងគ្រោះឆ្នាំ២០១៨» (ហៅកាត់ថា SIMVA) បានរកឃើញថា ក្រុមគ្រួសារនៅតែបន្តពឹងអាស្រ័យលើធនធានទឹកដែលកំពុងរងសម្ពាធកាន់តែខ្លាំងឡើង។

លោក អាន ពេជ្រហត្ថដា នាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC បានលើកឡើងថា ការសិក្សាស្រាវជ្រាវទាំងនេះ រំលេចបន្ថែមពីសារៈសំខាន់នៃការអភិវឌ្ឍប្រកបដោយទំនួលខុសត្រូវផលប្រយោជន៍ថ្នាក់ជាតិ និងតំបន់ដែលមានតុល្យភាព និងកិច្ចសហប្រតិបត្តិការតំបន់កាន់តែរឹងមាំបន្ថែមទៀត ដើម្បីរក្សាការពារធនធានទឹក និងធនធានពាក់ព័ន្ធនៃទន្លេមេគង្គ។

របាយការណ៍ទាំងពីរនេះ ផ្តល់អនុសាសន៍ឲ្យមានការគាំពារដល់បរិមាណត្រី ដើម្បីធានាឲ្យមានការផ្គត់ផ្គង់ស្បៀងសម្រាប់ប្រជាជនរាប់លានអ្នក ដែលកំពុងរស់នៅតាមអាងទន្លេមេគង្គក្រោម និងរក្សាការពារការធ្លាក់ចុះបន្ថែមទៀតនៃប្រាក់ចំណូលរបស់ក្រុមគ្រួសារ។

បើយោងតាម SIMVA ឆ្នាំ២០១៨ ក្នុងចំណោមក្រុមគ្រួសារចំនួន២.៨០០ មានគ្រួសារដែលស្ទង់មតិ ៣៥% បានលើកឡើងថា ប្រាក់ចំណូល របស់ពួកគេមានកម្រិតទាបជាងមុន ៣២% ថាស្ថានភាពចំណូលនៅតែដដែល មានតែ ២៦% ប៉ុណ្ណោះ ដែលថាប្រាក់ចំណូលបានកើនឡើងបន្តិចបន្តួច ខណៈដែល ៦% ទៀតបញ្ជាក់ថា វាបានកើនឡើងគួរឲ្យ កត់សម្គាល់ បើធៀបទៅនឹងឆ្នាំ២០១៣ ។

ការផ្លាស់ប្តូរអវិជ្ជមានក្នុងធនធានទឹករួមមានកសិកម្ម វារីវប្បកម្ម មច្ឆា និងសត្វ និងរុក្ខជាតិក្នុងទឹក ផ្សេងទៀត កំពុងជះឥទ្ធិពលលើប្រាក់ចំណូល ដោយ២២% នៃក្រុមគ្រួសារ បានបញ្ជាក់ថា ពួកគេរងផលប៉ះពាល់ពីបញ្ហានេះ។

របាយការណ៍ទាំងពីរនេះ បានលើកឡើងទៀតថា វានៅមានវិសាលភាពធំគួរឲ្យកត់សម្គាល់សម្រាប់ការធ្វើឲ្យប្រសើរឡើងវិញ ដែលរដ្ឋាភិបាលអាចរៀបចំចេញជាគោលនយោបាយប្រសិនបើសហគមន៍ត្រូវបានការពារពីភាពងាយរងគ្រោះដោយទឹកនិងភាពងាយរងគ្រោះពាក់ព័ន្ធនឹងការ ប្រែប្រួលអាកាសធាតុ។

ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៨ ការតាមដានត្រូវបានអនុវត្តរៀងរាល់ថ្ងៃ ដោយមន្ត្រីជំនាញផ្នែក ជលផល នៅតាមស្ថានីយចំនួន៣៨ តាមទន្លេមេនៃទន្លេមេគង្គ និងដៃទន្លេសំខាន់ៗ ក៏ប៉ុន្តែ ដោយសារ កត្តាកង្វះទិន្នន័យ មានតែទីតាំងចំនួន២៥ ប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ក្នុងនោះ ស្ថានីយចំនួន១១ ស្ថិតក្នុងប្រទេសកម្ពុជា, ៤នៅប្រទេសឡាវ និង៥ នៅប្រទេសថៃ និង វៀតណាម។

ក្រៅពីគម្រោងផ្តួចផ្តើមស្រាវជ្រាវ FDMA និង SIMVA លំហាត់តាមដានសង្គម-សេដ្ឋកិច្ចសំខាន់ៗ ផ្សេងទៀត ដែលបានរៀបចំដោយ MRC ក្រោមកិច្ចសហការជាមួយនឹងប្រទេសជាសមាជិក បានដាក់បញ្ចូលនូវរបាយការណ៍ស្តីពីស្ថានភាពអាងឆ្នាំ២០១៨ ដែលជាការស្រាវជ្រាវកម្រិតធំលើកដំបូង ដើម្បីប្រមូលនូវព័ត៌មានសង្គម-សេដ្ឋកិច្ចយ៉ាងទូលំទូលាយក្នុងអាងទន្លេមេគង្គ រួមទាំងអាងទន្លេមេគង្គផ្នែកខាងលើផងដែរ៕

# ក្រសួងបរិស្ថានអនុម័តប្លង់មេ និងផែនការអភិវឌ្ឍន៍វិនិយោគ ទេសចរណ៍ធម្មជាតិខ្នាតតូចចំនួន៥



*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងបរិស្ថានបានសម្រេចដាក់ឆ្លងនិងអនុម័តលើប្លង់មេនិងផែនការអភិវឌ្ឍន៍វិនិយោគទេសចរណ៍ធម្មជាតិខ្នាតតូចចំនួន ៥ ស្ថិតនៅក្នុងឧទ្យានជាតិព្រះមុនីវង្សបូកគោ ភូមិសាស្ត្រសង្កាត់ព្រែកត្នោត ខេត្តកំពត កាលពីចុងខែតុលាកន្លងមកនេះ ខណៈដែលមន្ត្រីជាន់ខ្ពស់នៃក្រសួងនេះជឿជាក់ថា គម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិខ្នាតតូចនេះនឹងចូលរួមបង្កើតសក្តានុពលទេសចរណ៍កាន់តែខ្លាំង និងមានជម្រើសកាន់តែច្រើនចូលរួមបង្កើតការងារ និង បង្កើនជីវភាពប្រជាពលរដ្ឋនៅជុំវិញតំបន់នោះ។

លោកនេត្រភក្ត្រារដ្ឋលេខាធិការក្រសួងបរិស្ថានបានគូសបញ្ជាក់ថា ទេសចរណ៍ធម្មជាតិផ្នែកមួយយ៉ាងសំខាន់ នៃទេសចរណ៍កម្ពុជា ហើយតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សចម្រុះដែលកំពុងត្រូវបានការពារបានយ៉ាងល្អប្រសើរបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញវិស័យទេសចរណ៍នៅក្នុងបរិការណ៍នៃការឆ្លងរីករាលដាលនៃជំងឺកូវីដ ១៩ នេះ។

លោកបានលើកឡើងថា ៖ «ក្នុងរយៈពេលចុងក្រោយនេះ ពលរដ្ឋខ្មែរបានដើរកម្សាន្តច្រើននៅតាមរមណីយដ្ឋាន និងតំបន់ទេសចរណ៍ធម្មជាតិនានាក្នុងប្រទេសកម្ពុជា និងបាននាំចូលសេដ្ឋកិច្ចជាច្រើនទៅមូលដ្ឋាន និងបង្កើតការងារថ្មីជូនពលរដ្ឋ ដែលជាផ្នែកមួយនៃ ការចូលរួមពង្រឹងលើកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ»។

លោក នេត្រ ភក្ត្រា បានលើកឡើងទៀតថា ប្រជាពលរដ្ឋខ្មែរកាន់តែច្រើនឡើង បានផ្តល់តម្លៃខ្ពស់នៃតំបន់ទេសចរណ៍ធម្មជាតិ និងមានមោទកភាពចំពោះសម្បត្តិ ធនធានរបស់កម្ពុជា ជាពិសេសតាមរយៈដំណើរកម្សាន្តនៅតាមរមណីយដ្ឋានទេសចរណ៍ធម្មជាតិនានា។

រូបភាព និងទេសភាពធម្មជាតិដ៏ស្រស់ត្រកាលនៃប្រទេសកម្ពុជាត្រូវបានចែករំលែកយ៉ាងទូលំទូលាយនៅតាមបណ្តាញទំនាក់ទំនងសង្គមនិង ប្រព័ន្ធផ្សព្វផ្សាយនានា ដែលបានចូលរួមកាន់តែខ្លាំងថែមទៀត ក្នុងការបណ្តុះស្មារតីស្រឡាញ់បរិស្ថាន និងធនធានធម្មជាតិក្នុងចំណោមប្រជាពលរដ្ឋខ្មែរ និងបានចូលរួមថែរក្សាការពារនូវទេសភាព និងសម្បត្តិធម្មជាតិទាំងនេះសម្រាប់មនុស្សជំនាន់តទៅមុខទៀត។ នេះបើតាមការបញ្ជាក់របស់លោក នេត្រ ភក្ត្រា៕

# យុវជនអាស៊ានសូមឲ្យគិតគូរបន្ថែមលើថាមពលកកើតឡើងវិញ




*អត្ថបទ៖ អរិយបុត្រ*

ប្រតិភូយុវជនអាស៊ានកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១ បានអំពាវនាវឲ្យតំបន់ពង្រឹងនិងជំរុញលើការផ្តោតចិត្តទុកដាក់លើការផ្លាស់ប្តូរថាមពលឆ្ពោះទៅរកប្រភពបៃតង និងបណ្តាប្រភពថាមពលក កើតឡើងវិញដើម្បីជាផ្នែកនៃកិច្ចសហប្រតិបត្តិការទាំងអស់គ្នានៅក្នុងការលើកកម្ពស់ក៏ដូចជាចូលរួមនៅក្នុងការកាត់បន្ថយបញ្ហាបម្រែបម្រួលអាកាសធាតុ។

ការអំពាវនាវបែបនេះ គឺត្រូវបានធ្វើឡើងដោយក្រុមយុវជនដែលបានចូលរួមនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីបរិស្ថានអាស៊ានជាមួយនឹងយុវជន ដែលបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ ដែលជាកិច្ចប្រជុំអមមួយនៃកិច្ចប្រជុំរដ្ឋមន្ត្រីបរិស្ថានអាស៊ានលើកទី១៦ ។

នៅក្នុងកិច្ចប្រជុំនោះ ប្រតិភូយុវជនអាស៊ានបានបង្ហាញនូវសេចក្តីប្រកាសបានដា សេរី បេហ្គាវ៉ាន់ (Bandar Seri Begawan) ស្តីពីយុវជនអាស៊ានសម្រាប់សកម្មភាពអាកាសធាតុដល់រដ្ឋមន្ត្រីបរិស្ថានអាស៊ាន។

សេចក្តីប្រកាសនេះបានគូសបញ្ជាក់ពីជំហររួមរបស់យុវជនអាស៊ានក្នុងតំបន់កង្វល់ និងអនុសាសន៍របស់ពួកគេក្នុងការពង្រឹងសកម្មភាពអាកាសធាតុ ហើយនៅក្នុងនោះ អ្វីដែលពួកគេ បានជំរុញ គឺការគិតគូរបន្តទៀតលើប្រភពថាមពលកកើតឡើងវិញ ដែលពួកគេជឿថា នេះគឺជាប្រភពថាមពលស្អាត និងមាននិរន្តភាពបរិស្ថាន។

ក្រុមយុវជនអាស៊ាន បានសង្កត់ធ្ងន់ថា តំបន់អាស៊ានស្ថិតក្នុងចំណោមតំបន់ដែលងាយរងគ្រោះបំផុតក្នុងពិភពលោកចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ គណៈប្រតិភូយុវជនអាស៊ានក៏បានអំពាវនាវឱ្យមានការពង្រឹងកិច្ចសហប្រតិបត្តិការលើការកាត់បន្ថយអាកាសធាតុនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិដោយផ្តោតលើការផ្លាស់ប្តូរថាមពលឆ្ពោះទៅរកធនធានថាមពលបៃតង និងកកើតឡើងវិញ។

ពួកគេបានសង្កត់ធ្ងន់លើតម្រូវការនៃការបង្កើតគោលដៅឆ្ពោះទៅរកមូលដ្ឋានវិទ្យាសាស្ត្រកាបូនីយកម្ម (science-based carbonisation) ដែលផ្អែកលើគោលការវិទ្យាសាស្ត្រដើម្បីឈានទៅសម្រេចបានគោលដៅនៃការបំភាយឧស្ម័នកាបូនិនសូន្យនៅក្នុងការរួមចំណែកដែលបានកំណត់ថ្នាក់ជាតិរបស់ប្រទេសនីមួយ។

ក្រុមយុវជនអាស៊ានក៏បានជំរុញឲ្យយុវជនគួរតែបម្រើតួនាទីដ៏មានអត្ថន័យ-ពីថ្នាក់មូលដ្ឋានដល់ថ្នាក់តំបន់- ក្នុងដំណើរការគោលនយោបាយ និងការសម្រេចចិត្ត។

ពាក់ព័ន្ធនឹងការជំរុញនេះ បណ្តារដ្ឋមន្ត្រីបរិស្ថានអាស៊ានបានសាទរ និងស្វាគមន៍ចំពោះសេចក្តីថ្លែងការណ៍បានដោយសេរី បេហ្គាវ៉ាន់ ស្តីពីយុវជនអាស៊ានសម្រាប់សកម្មភាពអាកាសធាតុ និងបានគាំទ្រនូវអនុសាសន៍ដែលប្រតិភូយុវជនអាស៊ានបានដាក់ចេញសម្រាប់ការពិចារណាបន្ថែម។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងដោយ ប្រទេសឥណ្ឌូនេស៊ី ហើយកិច្ចសន្ទនានេះមានការចូលរួមពីរដ្ឋមន្ត្រីបរិស្ថានអាស៊ាន អគ្គលេខាធិការអាស៊ាន និងប្រតិភូយុវជនអាស៊ានទាំង១០ ៕





# ប្រទេសដែលហូបស្វាយកម្ពុជាឥឡូវមាន ជាង១០ប្រទេស

*អត្ថបទ៖ អរិយបុត្រ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា មកដល់ពេលនេះប្រទេសដែលហូបស្វាយកម្ពុជាទាំងស្រស់និងកែច្នៃគឺមានរហូតដល់ទៅជាង ១០ ប្រទេស ។

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងនេះ បានផ្សព្វផ្សាយថ្មីៗនេះនូវបញ្ជីផលិតផលកសិកម្មនាំចេញ ហើយនៅក្នុងនោះ គឺមានផលិតផលស្វាយផងដែរ ។

នៅក្នុងបញ្ជីនៃការនាំចេញនេះ ប្រទេសនិងដែនដីដែលហូបស្វាយកម្ពុជាទាំងស្រស់និងកែច្នៃគឺមាន ប្រទេសវៀតណាម ថៃ ចិន កូរ៉េខាងត្បូង កោះហុងកុង សិង្ហបុរី គុយវ៉ែត ហ្វីលីពិន ជប៉ុន អង់គ្លេស អាមេរិក កោះតៃវ៉ាន់ កាហ្សាក់ស្ថាន និងប្រទេសរុស្ស៊ី ។

ប្រភពដដែលបានបន្តថា ផលិតផលផ្លែស្វាយស្រស់កម្ពុជាបាននាំចេញផលិតផលទាំងនេះនៅក្នុងចំនួន ២០២.១៤២ តោន កើនឡើងចំនួន ១៥៧,៨៣% ដោយនាំចេញទៅប្រទេសវៀតណាមចំនួន ១៧៤.៧៦៥ តោន ប្រទេសថៃចំនួន ២៦.៩៦៩ តោន ប្រទេសចិនចំនួន ២១៦ តោន ប្រទេសកូរ៉េចំនួន ១២៤ តោន ទីក្រុងហុងកុងចំនួន ៥១ តោន ប្រទេសសិង្ហបុរីចំនួន ១៦ តោន និងប្រទេសគុយវ៉ែតចំនួន ០,០១ តោន។

ប្រភពដដែលបានបន្តថា នៅលើផលិតផលដំណាប់ស្វាយវិញគឺកម្ពុជាបាននាំចេញមានចំនួន សរុប១៥.៦៥១ តោន កើនឡើងចំនួន ១៩៥,៤១% ដោយ នាំចេញទៅប្រទេសចិនចំនួន១២.៣៣១ តោន, ប្រទេសថៃចំនួន ១ ៣១៥ តោន, ប្រទេសហ្វីលីពីនចំនួន ៨៨៤ តោន, ប្រទេសវៀតណាម ចំនួន ៥៥៩ តោន, ប្រទេសជប៉ុនចំនួន ៥១២,៥០ តោន, ចក្រភពអង់គ្លេស ២១ តោន, ប្រទេសកូរ៉េចំនួន ១៧,៥០តោន, សហរដ្ឋអាមេរិកចំនួន ៨,៥៦ តោន, កោះតៃវ៉ាន់ចំនួន ៣ តោន, ប្រទេសកាហ្សាក់ស្ថានចំនួន ០,០៥ តោន និងប្រទេសរុស្ស៊ីចំនួន ០,០០២ តោន។

ប្រភព ដដែលបាន បន្ថែមទៀតថា លើផលិតផលទឹកស៊ីរ៉ូស្វាយ កម្ពុជាបាននាំចេញសរុបចំនួន ៤.៤០០,៨៩ តោន កើនឡើងចំនួន ៤១,០៤% ដោយនាំចេញទៅប្រទេសហ្វីលីពីនចំនួន ៤.២៥៣ តោន និងប្រទេសចិនមានចំនួន ១៤៨ តោន។

រហូតមកដល់ពេលនេះបើជាផលិតផលស្វាយស្រស់និងកែច្នៃនៅតែមានទីផ្សារនាំចេញទៅក្រៅប្រទេស ប៉ុន្តែ កសិករដាំស្វាយនៅតែត្អូញត្អែរថា អត់ទីផ្សារ ហើយមានតម្លៃថោក ។

លោក ជា សឿន ជាកសិករមួយរូបនៅខេត្តកណ្តាលបានអះអាងថា គាត់មានចំការស្វាយកែវរមៀតប្រមា ណ ជា ១ ហតដែរ ប៉ុន្តែតម្លៃគឺថោកមែនទែន គឺមួយគីឡូត្រឹមតែ ១០០ ទៅ ២០០ រៀលប៉ុណ្ណោះ ប៉ុន្តែប្រសិនបើផ្លែបានមុនរដូវ បន្តិចតម្លៃអាចប្រសើរ គឺអាចបាន ១០០០ទៅ ២០០០ រៀល អីដែរ៕





## ប្រមូលផលស្ពៃក្នុងរដូវរំហើយ

កសិករកំពុងប្រមូលផលស្ពៃរបស់ខ្លួន។ ជាដំណាំបន្លែស្លឹកដែលអាចដាំដុះគ្រប់រដូវ ហើយឆាប់ទទួលបានផលដែលកសិករខ្មែរយើងនិយមដាំច្រើន ការដាំស្ពៃបានផលល្អបំផុតនៅរដូវរំហើយចាប់ពីខែតុលា ខែវិច្ឆិកា និងខែធ្នូ។ បន្លែស្ពៃភាគច្រើនគេយកវាទៅធ្វើម្ហូបដូចជាឆា ស្ងោរ ឬធ្វើជាអន្លក់ស្រស់ ជាដើម។ *រូបភាព៖ ស៊ីអេសស៊ី*

# កម្ពុជារំពឹងថា នឹងនាំចេញទំនិញទៅកាន់ប្រទេសកូរ៉េខាងត្បូងកាន់តែច្រើន

*អត្ថបទ៖ អរិយបុត្រ*

ក្រោយពេលដែលកម្ពុជានិងកូរ៉េខាងត្បូងបានចុះហត្ថលេខាលើកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីភ្លាម លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអះអាងថា ប្រទេសកូរ៉េខាងត្បូងក៏ជាដៃគូពាណិជ្ជកម្មដ៏សំខាន់មួយរបស់កម្ពុជាផងដែរ ជាពិសេសលើ ផលិតផលនៃវិស័យកសិកម្ម។



លោកបានអះអាងថា នៅក្នុងរយៈពេល៩ខែ ឆ្នាំ២០២១ កម្ពុជាបាននាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារនៅកូរ៉េខាងត្បូងចំនួនប្រមាណជា ១.២០៥ តោន។ ខណៈដែលកាលពីឆ្នាំ២០២០ គឺមានត្រឹមតែ ៥៨៥ តោនប៉ុណ្ណោះ។

លោកបានបន្តថា កាលពីឆ្នាំ២០១៩ មុនបរិបទកូវីដ ១៩ ទំនិញកសិកម្មកម្ពុជាដែលនាំចេញទៅកាន់កូរ៉េខាងត្បូងគឺមានទំហំរហូតដល់ទៅ ជាង ៦.០០៨ តោនឯណោះ។

លោកបានបន្តថា ទំនិញកសិកម្មកម្ពុជាដែលនាំចេញទៅកូរ៉េខាងត្បូងមកដល់ពេលនេះ គឺមានចំនួន ប្រមាណជា ៤៧ មុខរាប់ចាប់តាំងពីស្លឹកទៀបបារាំង ញក្រៀម ដៃត្លៃ ស្អំសម្លួត រំដេងត្រសក់ចាវ បំពេញរាជ្យត្រាំ និងក្រូចង៉ាំង៉ូវ។

គួររំលឹងថា នៅថ្ងៃដដែលនេះដែរ លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោក យ៉ោវ ហាន់កូ (YEO Han-Koo) រដ្ឋមន្ត្រីពាណិជ្ជកម្ម កូរ៉េខាងត្បូងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនឹងគ្នា។





ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជានិងកូរ៉េខាងត្បូងនេះ ជាគំនិតផ្តួចផ្តើមរបស់សម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ លោក មូនជេអ៊ីន (MOON Jae-In) ប្រធានាធិបតីកូរ៉េខាងត្បូង មកកាន់ព្រះរាជាណាចក្រកម្ពុជា កាលពីខែមីនា ឆ្នាំ២០១៩ កន្លងទៅ សំដៅពង្រឹង និងពង្រីកចំណងមិត្តភាព សេដ្ឋកិច្ច និងពាណិជ្ជកម្មនៃប្រទេសទាំងពីរ។

អនុវត្តតាមអាណត្តិផ្តល់ឱ្យដោយថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ រដ្ឋមន្ត្រីពាណិជ្ជកម្មនៃប្រទេសទាំងពីរបានប្រកាសចាប់ផ្តើមការសិក្សារួមកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េខាងត្បូង។ ការសិក្សាបានបង្ហាញលទ្ធផល វិជ្ជមានសម្រាប់ប្រទេសទាំងពីរ ដោយនឹងពង្រឹងភាពជាដៃគូសេដ្ឋកិច្ច និងពង្រីកការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មទ្វេភាគីឱ្យកាន់តែទូលំទូលាយ ដោយផ្តល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក សំដៅបង្កើនផលប្រយោជន៍សេដ្ឋកិច្ច និងសុខមាលភាព ប្រជាជន និងធុរកិច្ចនៃប្រទេសទាំងពីរ។



កិច្ចព្រមព្រៀងនេះ ត្រូវបានប្រកាសបើកការចរចាជាផ្លូវការនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីដេអូ ដោយរដ្ឋមន្ត្រីពាណិជ្ជកម្មនៃប្រទេសទាំងពីរ និងឆ្លងកាត់ការចរចាសរុបចំនួន ១២លើកមុននឹងឈានមកដល់ការចុះហត្ថលេខានាពេលនេះ។ នេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមោះមុតរបស់ភាគីទាំងពីរ ក្នុងការជំនះពុះពាររាល់ឧបសគ្គ ទោះបីជាស្ថិតក្នុងស្ថានភាពលំបាកដែលបង្កឡើងជំងឺកូវីដ-១៩ រហូតសម្រេចបានសមិទ្ធផលជាប្រវត្តិសាស្ត្រដ៏មានសារៈសំខាន់នេះ។

កិច្ចព្រមព្រៀងនេះមានចំនួន ១០ជំពូក មាន ១៣១មាត្រា រួមទាំងបុព្វកថា និងឧបសម្ព័ន្ធចំនួន ៩ ដែលគ្របដណ្តប់លើពាណិជ្ជកម្មទំនិញ ដែលក្នុងនោះរួមមាន ស្តង់ដារបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម វិធានការអនាម័យ និងភូតគាមអនាម័យ និងគ្របដណ្តប់ផងដែរលើ ឧបាស្រ័យពាណិជ្ជកម្ម វិធានដើមកំណើត នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តម្លាភាព យន្តការដោះស្រាយវិវាទអញ្ញត្រកម្ម ការរៀបចំស្ថាប័ន និងអវសានប្បញ្ញត្តិ។

លើសពីនេះទៀត កិច្ចព្រមព្រៀងនេះនឹងជំរុញកំណើននៃការនាំចេញ កំណើនផលទុនសរុបក្នុងស្រុក និងកំណើនឱកាសការងារ ព្រមទាំងជួយស្តារឡើងវិញនូវសេដ្ឋកិច្ច របស់ប្រទេសទាំងពីរបានឆាប់រហ័ស ដែលទទួលរងផលប៉ះពាល់ជំងឺកូវីដ-១៩ ដោយនឹងពង្រីកបន្ថែមការធ្វើសេរីភាវូបនីយកម្មទីផ្សារ បន្ថែមពីលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA) និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។

ជាពិសេស កិច្ចព្រមព្រៀងនេះនឹងជំរុញការនាំចេញរបស់កម្ពុជាទៅកាន់សាធារណរដ្ឋកូរ៉េបន្ថែមទៀត ដូចជា ផលិតផលសម្លៀកបំពាក់ និងវាយនភណ្ឌ ស្បែកជើង កាបូប គ្រឿង បន្លាស់ឧបករណ៍អេឡិចត្រូនិក កៅស៊ូ និងផលិតផលកសិកម្ម ជាដើម។

សូមបញ្ជាក់ផងដែរថា កិច្ចព្រមព្រៀង CKFTA នេះ នឹងចូលជាធរមានក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីភាគីទាំងពីរ ជូនដំណឹងទៅវិញទៅមកតាមផ្លូវការទូត អំពីការបញ្ចប់នីតិវិធីផ្ទៃក្នុងនៃការផ្តល់សច្ចាប័ន៕

# ផ្សោតទន្លេមេគង្គ
## អន្លង់ឈើទាល-ព្រំដែនកម្ពុជានិងឡាវ
# កំពុងបាត់បង់ទាំងស្រុង




*អត្ថបទ៖ អមរិន្ទ ដានុត*

រដ្ឋបាលជលផល អង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ (WWF) និងអង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (IUCN) បានលើកឡើងពីការបារម្ភនៃការឈានទៅដល់បាត់បង់សត្វផ្សោតទន្លេមេគង្គ (Orcaella brevirostris) ដែលរស់នៅ ក្នុងអន្លង់ឈើទាល ស្ថិតជាប់នឹងព្រំប្រទល់នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កំពុងឈានទៅបាត់បង់ទាំងស្រុង។

សត្វផ្សោតទន្លេមេគង្គ ត្រូវបានអ្នកវិទ្យាសាស្ត្រចាត់ថ្នាក់ក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទសត្វជិតផុតពូជ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សត្វផ្សោតទាំងនេះកំពុងរស់នៅតាមទីជម្រកសំខាន់ៗនៃទន្លេមេគង្គ ចាប់ពីទីរួមខេត្តក្រចេះ រហូតដល់ព្រំប្រទល់នៃប្រទេសឡាវត្រង់ប៉ែកខាងក្រោមនៃល្បាក់ខោន ដែលមានចម្ងាយ១៨០គម។

លទ្ធផលជំរឿនសត្វផ្សោតក្នុងឆ្នាំ ២០២០ បានប៉ាន់ប្រមាណថាមានចំនួនត្រឹមតែ៨៩ ក្បាលប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលចំនួនកូនផ្សោតដែលបានកត់ត្រាថ្មី។ ក្រុមសត្វផ្សោតដែលរស់នៅក្នុងអន្លង់ឈើទាល គឺជាក្រុមរស់នៅដាច់ដោយឡែកពីក្រុមសត្វផ្សោតដទៃទៀត ដែលកំពុងរស់នៅតាមដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា។

សេចក្តីប្រកាសរួមនេះបានលើកឡើងថា ផ្អែកតាមការសិក្សាអង្កេត ចំនួនសត្វផ្សោតនៅអន្លង់ឈើទាលបានថយចុះជាបន្តបន្ទាប់មកត្រឹម៣ក្បាលក្នុងឆ្នាំ២០១៨ និង១ក្បាលក្នុងឆ្នាំ២០២១ ។

លោកបណ្ឌិត Randall Reeves ប្រធានក្រុមអ្នកជំនាញវិទ្យាសាស្ត្រផ្នែកពពួកថនិកសត្វទឹកនៃអង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (IUCN) បានឱ្យដឹងថា សត្វផ្សោតនៃអន្លង់អន្តរព្រំដែនឡាវ-កម្ពុជានឹងឈានទៅបាត់បង់ហើយ ដោយសារវានៅសេសសល់ចំនួនតិចតួចណាស់ ហើយត្រូវបានអ្នកវិទ្យាសាស្ត្រដឹងថាវាបានរស់នៅដាច់ឆ្ងាយពីហ្វូងធំៗដទៃទៀត ដែលកំពុងរស់នៅក្នុងអន្លង់នៃខ្សែទឹកខាងក្រោមទន្លេមេគង្គក្នុងខេត្តក្រចេះ និងស្ទឹងត្រែង។

ចំណែកលោក ពុំ សុថា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលបានមានប្រសាសន៍ថា៖ «ការថយចុះចំនួនសត្វផ្សោតនៅអន្លង់ឈើទាលដែលនឹងឈានទៅបាត់បង់នាពេលខាងមុខ ជាសញ្ញាប្រកាសអាសន្នមួយដល់អនាគតនៃថនិកសត្វដ៏សំខាន់ប្រភេទនេះ។ បច្ចុប្បន្ន ទោះបីជា សត្វផ្សោតនៅសល់តែចំនួនមួយក្បាលក្នុងអន្លង់ឈើទាលនេះក៏ដោយ ក៏រដ្ឋបាលជលផលនៅតែបន្តខិតខំការពារ និងពង្រឹងកិច្ចសហការជាមួយភាគីឡាវ ក្នុងការគ្រប់គ្រងធនធានជលផលដ៏មានតម្លៃនេះ»។

លោកបានបន្ថែមទៀតថា សត្វផ្សោតទន្លេមេគង្គត្រូវបានការពារ និងអភិរក្សយ៉ាងតឹងរឹង ដោយច្បាប់ស្តីពីជលផល និងអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គនៃប្រទេសកម្ពុជា។

លោក ពុំ សុថា បានបញ្ជាក់ថា៖ «សូមអាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ ពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ បន្ថែមទៀត ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅតំបន់អន្តរព្រំប្រទល់ ដែលជាប្រយោជន៍ដល់សហគមន៍មូលដ្ឋាននៃប្រទេសទាំងពីរ និងការរស់រាននៃសត្វផ្សោតដែលនៅសល់ក្នុងអន្លង់ឈើទាលនេះ»។



បើតាមសេចក្តីប្រកាសរួមនេះ អន្លង់ឈើទាលនេះរងនូវហានិភ័យខ្ពស់ ដែលធ្វើឱ្យសត្វផ្សោតរស់ក្នុងអន្លង់នោះបានស្លាប់ជាបន្តបន្ទាប់ ដោយសារការប្រែប្រួលរបបទឹកផ្នែកខាងលើនៃទន្លេមេគង្គ និងកិច្ចសហការក្នុងការទប់ស្កាត់ការនេសាទដោយប្រើឧបករណ៍ហាមឃាត់ក្នុងតំបន់ព្រំដែននៃប្រទេសទាំងពីរ។

ម្យ៉ាងទៀត សត្វផ្សោតមួយចំនួននៅអន្លង់ឈើទាលនេះក៏បានស្លាប់បណ្តាលមកពីអាយុកាលផងដែរ។ ចំនួនសត្វផ្សោតនៃអន្លង់អន្តរព្រំដែនឡាវ-កម្ពុជា បានធ្លាក់ចុះជាបន្តបន្ទាប់នេះ អ្នកវិទ្យាសាស្ត្របានប្រកាសរួចមកហើយកាលពីឆ្នាំ ២០១៦ ថា ហ្វូងផ្សោតដែលរស់នៅក្នុងអន្លង់ឈើទាលនេះនឹងឈានទៅផុតពូជនៅថ្ងៃខាងមុខ។

សត្វផ្សោតទន្លេមេគង្គបានប្រឈមនឹងការគំរាមកំហែងកាន់តែខ្លាំងឡើងៗអស់រយៈកាលជាច្រើនទសវត្សរ៍មកហើយ។ កត្តាគំរាមកំហែងដែលជាមូលហេតុចំបងៗដែលបានបណ្តាលឱ្យចំនួនសត្វផ្សោតនៅក្នុងអន្លង់អន្តរព្រំដែនធ្លាក់ចុះជាបន្តបន្ទាប់រួមមានការស្លាប់ដោយ






> ការថយចុះចំនួនសត្វផ្សោតនៅអន្លង់ឈើទាលដែលនឹងឈានទៅបាត់បង់នាពេលខាងមុខ ជាសញ្ញាប្រកាសអាសន្នមួយដល់អនាគតនៃថនិកសត្វដ៏សំខាន់ប្រភេទនេះ។ ទោះបីជា សត្វផ្សោតនៅសល់តែចំនួនមួយក្បាលក្នុងអន្លង់ឈើទាលនេះក៏ដោយ ក៏រដ្ឋបាលជលផលនៅតែបន្តខិតខំការពារ និងពង្រឹងកិច្ចសហការជាមួយភាគីឡាវ ក្នុងការគ្រប់គ្រងធនធានជលផលដ៏មានតម្លៃនេះ។

ជាប់នឹងមងនេសាទ ការអភិវឌ្ឍទំនប់វារីអគ្គីសនីនៅខ្សែទឹកបែកខាងលើមេគង្គដែលបង្កការរាំងនូវលំហូរទឹកជាធម្មជាតិ ការនេសាទហួសកំម្រិត និងការអនុវត្តវិធីសាស្ត្រនេសាទបែបបំផ្លាញ ដូចជាការប្រើឧបករណ៍ឆក់ជាដើម។ កត្តាគំរាមកំហែងទាំងនេះក៏កំពុងបន្តដាក់សម្ពាធខ្លាំងឡើងៗលើការរស់រានមានជីវិតរបស់សត្វផ្សោតនៃទន្លេមេគង្គទាំងមូល។

នៅក្នុងឆ្នាំ ២០២០ និងក្នុងឆមាសទី ១ នៃឆ្នាំ ២០២១ នេះ ការងារល្បាតតាមទីជម្រករបស់សត្វផ្សោត តាមបណ្ដោយដងទន្លេមេគង្គ ក្នុងខេត្តក្រចេះ និងស្ទឹងត្រែង បានសម្រេចបានលទ្ធផលសំខាន់ៗដូចជាការរឹបអូសនូវមងនេសាទខុសច្បាប់ សរុបប្រវែងប្រមាណ ១១២.០០០ ម៉ែត្រ ព្រមទាំងរឹបអូសនូវសន្ទូចរនងដាក់ក្នុងទីជម្រកផ្សោតសរុបប្រវែងប្រមាណជាង ១៣១.០០០ ម៉ែត្រផងដែរ។ ការងារល្បាតក៏បានទប់ស្កាត់និងរឹបអូសផងដែរនូវការនេសាទដោយឧបករណ៍ឆក់សរុបចំនួន ២០ ករណីផងដែរ។

អ្នកសម្របសម្រួលកម្មវិធីអភិរក្សសត្វផ្សោតទន្លេ និងប្រព័ន្ធទន្លេប្រចាំតំបន់អាស៊ីនៃអង្គការ WWF និងជាសមាជិកនៃក្រុមអ្នកជំនាញវិទ្យាសាស្ត្រផ្នែកពពួកថនិកសត្វទឹកនៃអង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (IUCN) លោកស្រីបណ្ឌិត Uzma Khan ក៏បានថ្លែងឱ្យដឹងដែរថា ៖ «យើងកំពុងតែមើលឃើញការបាត់បង់ដ៏គួរឱ្យសោកសង្រេងនូវសត្វផ្សោតអន្តរព្រំប្រទល់ ដែលជាសត្វនិមិត្តរូបដ៏សំខាន់មួយប្រភេទនេះ។ វាពិតជាការសោកស្ដាយមួយដ៏ខ្លាំងពន់ពេក»។

លោកស្រី បានបន្ថែមទៀតថា ខណៈពេលដែលការឈានជិតទៅផុតពូជរបស់សត្វផ្សោតនៃអន្លង់អន្តរព្រំប្រទល់នឹងចូលមកដល់ លោកស្រីសូមអំពាវនាវដល់រដ្ឋាភិបាលឡាវ និងកម្ពុជាក្នុងការរួមសហការគ្នាដើម្បីបញ្ឈប់ការប្រើប្រាស់មង និងវិធីនេសាទខុសច្បាប់ដទៃៗទៀតទាំងនៅក្នុង និងជុំវិញអន្លង់អន្តរព្រំប្រទល់ ក៏ដូចជារួមគ្នាបន្ទាន់ដើម្បីរៀបចំផែនការស្ដារឡើងវិញនូវទីជម្រកដោយរក្សា និងធានាឱ្យបាននូវលំហូរទឹកជាធម្មជាតិសម្រាប់ការរស់រានរបស់សត្វផ្សោត និង ត្រីមេពូជផ្សេងៗជាច្រើនប្រភេទទៀត។

ទន្ទឹមនឹងនេះដែរ លោក ពុំ សុថា និងលោក សេង ទៀក នាយកអង្គការ WWF ប្រចាំប្រទេសកម្ពុជា បានឯកភាពគ្នាថា នាពេលអនាគត ប្រសិនបើសត្វផ្សោតមួយក្បាលដែលកំពុងរស់នៅក្នុងអន្លង់ឈើទាលនេះ បានបាត់បង់បន្ថែមទៀត រដ្ឋបាលជលផល និងអង្គការ WWF នឹងរៀបចំធ្វើរូបសំណាកសត្វផ្សោត ដាក់តាំងនៅលើច្រាំងទន្លេមេគង្គនៃអន្លង់ឈើទាល ដើម្បីរំលឹកដល់សាធារណៈជន និងកូនចៅជំនាន់ក្រោយបានចងចាំនូវវត្តមានសត្វផ្សោត ដែលធ្លាប់រស់នៅទីនោះ៕



# អង្គការសង្គមស៊ីវិលអំពាវនាវឱ្យបន្ទឹងការប្រយុទ្ធប្រឆាំងនិទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន

*អត្ថបទ៖ អមរិន្ទ ដានុត*

នៅក្នុងទិវាអន្តរជាតិបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន នាដើមខែវិច្ឆិកា ឆ្នាំ២០២១ អង្គការសង្គមស៊ីវិលចំនួន៩ស្ថាប័ន បានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបរាជ័យរបស់រដ្ឋាភិបាលកម្ពុជាក្នុងការចាប់អ្នកប្រព្រឹត្តបទល្មើសនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើអ្នកសារព័ត៌មាននៅក្នុង ប្រទេសកម្ពុជាមកផ្តន្ទាទោស។

ក្រុមអង្គការសង្គមស៊ីវិលបានទទូចឱ្យអាជ្ញាធរកម្ពុជាចាត់វិធានការជាបន្ទាន់ដើម្បីធានាឱ្យមានការស៊ើបអង្កេត ប្រកបដោយប្រសិទ្ធភាពឯករាជ្យភាព និងតម្លាភាពទៅលើគ្រប់ករណីបទល្មើសទាំងអស់ដែលបានកើតឡើង និងយុត្តិធម៌ ត្រូវបានផ្តល់ជូនដល់ជនរងគ្រោះនិងសាច់ញាតិរបស់ពួកគេ។

យោងតាមសេចក្តីថ្លែងការណ៍រួម បានលើកឡើងថា ចាប់តាំងពីឆ្នាំ ១៩៩៤មក យ៉ាងតិចណាស់មានអ្នកសារព័ត៌មានចំនួន ១៧នាក់ត្រូវបានសម្លាប់ និងស្លាប់នៅកម្ពុជា។ ករណីស្ទើរតែទាំងអស់ជនរងគ្រោះត្រូវបានសម្លាប់ដោយសារតែការងាររបស់ពួកគេ។

សេចក្តីថ្លែងការណ៍បានបន្តថា ជាក់ស្តែងការស្លាប់របស់ជនរងគ្រោះចំនួន ១២នាក់ក្នុងចំណោម ១៧នាក់ខាងលើគឺពួកគេត្រូវបានសម្លាប់ក្នុងខណៈពួកគេបានធ្វើការរាយការណ៍ ព័ត៌មានអំពីបញ្ហារសើប។ ក្នុងចំណោមករណីទាំង១៧ មាន១២ករណីដែលអ្នកប្រព្រឹត្តបទល្មើសមិនត្រូវបាននាំយកមកផ្ត ន្ទាទោសពីបទឃាតកម្មលើអ្នកសារព័ត៌មានទាំងអស់នោះទេ។

អង្គការសង្គមស៊ីវិលបានបញ្ជាក់ថា ៖ «ឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន និងការធ្វើទុក្ខបុកម្នេញលើអ្នកសារព័ត៌មានហាក់នៅតែកើតឡើងជាបន្តបន្ទាប់គួរឱ្យព្រួយបារម្ភ»។

ប្រភពដដែលបានបន្តថា ក្នុងរយៈពេល ១០ខែចុងក្រោយនេះ (ចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២១) សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) បានរកឃើញថា មានអ្នកសារព័ត៌មានសរុប ៨១ នាក់ បានទទួលរង នូវការធ្វើទុក្ខបុកម្នេញ ក្នុងរូបភាពផ្សេងៗ ។ ក្នុងនោះមានអ្នកសារព័ត៌មាន ចំនួន ៣១នាក់ (ស្រី៤នាក់) ត្រូវបានចាប់ខ្លួន ២០នាក់ទទួលរងការប្រើអំពើហិង្សា ១៦នាក់ទទួលរងការគំរាមកំហែង ៨នាក់ទទួលរងពាក្យបណ្តឹងពីតុលាការ ៥នាក់ទទួលរងការឃាត់ខ្លួនដើម្បីសួរចម្លើយ និងអ្នកសារព័ត៌មានស្រី ១នាក់ទទួល រងការបៀតបៀនផ្លូវភេទ។

ឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មានមានលក្ខណៈធ្ងន់ធ្ងរ និងជាការគំរាមកំហែងយ៉ាងពិតប្រាកដ ហើយមិនត្រឹម តែចំពោះអ្នកសារព័ត៌មានប៉ុណ្ណោះទេ។

សេចក្តីថ្លែងការណ៍បានបន្តថា អ្នកសារព័ត៌មានមានបេសកកម្មយ៉ាងសំខាន់ក្នុងការរាយការណ៍ហេតុការណ៍ដែល បានកើតឡើងសរសេរបទវិភាគ និងបទអត្ថាធិប្បាយ ដើម្បីគាំទ្រឱ្យមានការបញ្ចេញមតិ និងជជែកពិភាក្សាយ៉ាងរស់រវើក។ អ្នកសារព័ត៌មានឯករាជ្យ ដើរតួយ៉ាងសំខាន់ក្នុងការទាមទារឱ្យអ្នកមានអំណាចមានទំនួលខុសត្រូវ និងរួមចំណែកយ៉ាង សំខាន់ទៅក្នុងសង្គមដែលមានយុត្តិធម៌។

អង្គការសង្គមស៊ីវិលទាំង៩នេះបានធ្វើការថ្កោលទោសចំពោះនិទណ្ឌភាពដែលឧក្រិដ្ឋកម្ម ប្រព្រឹត្តលើអ្នកសារព័ត៌មានត្រូវបានកើតមាននៅក្នុងប្រទេសកម្ពុជា ដែលធ្វើឱ្យប៉ះពាល់ដល់សង្គមកម្ពុជាទាំងមូល។

អង្គការសង្គមស៊ីវិលថា ៖ «យើងខ្ញុំ សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឱ្យចាត់វិធានការជាក់ស្តែង ដើម្បីធានាថាការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះត្រូវបានធ្វើឡើងហើយជនល្មើសត្រូវបាន នាំមកផ្តន្ទាទោស»។

ប្រភពដដែលថា ៖ «យើងក៏ សូមឱ្យរាជរដ្ឋាភិបាលចាត់វិធានការជាបន្ទាន់ ដើម្បីធានាសុវត្ថិភាព និងសន្តិសុខដល់អ្នកសារព័ត៌មានគ្រប់រូប ដើម្បីឱ្យពួក គេអាចអនុវត្តសិទ្ធិសេរីភាព ចូលរួមរាយការណ៍ព័ត៌មាននានាដែលកំពុងកើតមានឡើងនៅក្នុងសង្គមដោយមិនមានភាព ភ័យខ្លាច»។

អង្គការសង្គមស៊ីវិលទាំងនេះរួមមាន៖ អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT), អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV), សមគមកម្ពុជាដើម្បីការពារអ្នកកាសែត (CAPI), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM), សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា), មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL), គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (COMFREL) និងសហព័ន្ធអ្នកសារព័ត៍អន្តរជាតិ (IFI)៕

# បុគ្គលិកCNC ស្វែងរកអ្នកច្បាប់ដើម្បីធានអត្ថប្រយោជន៍ស្របច្បាប់ក្រោយពីការបណ្តេញចេញពីការងារ

*អត្ថបទ៖ ផល សុផានិត*

ក្រុមបុគ្គលិកទូរទស្សន៍CNC នៃក្រុមហ៊ុនCBS កាលពីចុងខែតុលា កន្លងមកបានកំពុងស្វែងរកអ្នកច្បាប់ឱ្យជួយពិនិត្យលើអត្ថប្រយោជន៍ដែលត្រូវទទួលបានតាមនីតិវិធី ក្រោយខាងក្រុមហ៊ុនសម្រេចបណ្តេញចេញ ក្រោមហេតុផលកាត់បន្ថយបុគ្គលិកព្រោះវិបត្តិហិរញ្ញវត្ថុ។

ក្រុមបុគ្គលិកផ្នែកព័ត៌មាន អ្នកកាត់ត អ្នកសម្របសម្រួលកម្មវិធី ចំនួន២២នាក់ នៃទូរទស្សន៍ CNC មានអតីតភាពការងារចន្លោះពី១០ខែ រហូតដល់ជាង១៩ឆ្នាំ ត្រូវបានបណ្តេញចេញជាបន្តបន្ទាប់ ហើយការបណ្តេញចេញនេះត្រូវបុគ្គលិកលើកឡើងថា គ្មានតម្លាភាពនោះទេ អ្នកចូលក្រោយនៅកៀកមេៗមិនឃើញបណ្តេញចេញទេ។

ក្រុមបុគ្គលិកទាំងនេះបានបញ្ជាក់ថា ភាគីក្រុមហ៊ុនបានបណ្តេញបុគ្គលិកក្រោមហេតុផលការចំណាយថវិការច្រើនមិនមានប្រាក់ចំណេញ ដែលត្រូវការកាត់បន្ថយបុគ្គលិកមួយចំនួនទៅតាមផ្នែកនៃក្រុមហ៊ុនCBS ក្នុងនោះCNCក៏ស្ថិតក្នុងដំបូលនេះដែរ។

ការបណ្តេញចេញដោយមិនមានកំហុសនេះបុគ្គលិកមិនបដិសេដទេ តែសូមឱ្យអនុវត្តផលប្រយោជន៍ជាសំណងទៅតាមច្បាប់លើកិច្ចសន្យាការងារមិនកំណត់ថេរវេលារវាងពួកគាត់និងក្រុមហ៊ុនសព្វថ្ងៃ ខណៈការបញ្ឈប់នេះភាគីក្រុមហ៊ុនបានផ្តល់ឱ្យមានដូចជាប្រាក់អតីតភាពគិតតែបីឆ្នាំចុងក្រោយ, ប្រាក់ឈប់សម្រាកប្រចាំឆ្នាំ (គិតតែមួយឆ្នាំចុងក្រោយ) និងប្រាក់បំណាច់ជួសការជូនដំណឹង ៤ប្រាក់ខែចុងក្រោយ។

ចំណែកការទាមទាររបស់អតីតបុគ្គលិក គឺសូមឱ្យក្រុមហ៊ុនគិតឱ្យត្រឹមត្រូវតាមច្បាប់ការងារដូចជាគិតប្រាក់ជំនួសការឈប់សម្រាកប្រចាំឆ្នាំតាមអតីតភាពការងារចាប់តាំងពីធ្វើការបាន១ឆ្នាំដំបូង,ឱ្យក្រុមហ៊ុនគិតប្រាក់អតីតភាព១៥ថ្ងៃក្នុង១ឆ្នាំទៅតាមអតីតភាពការងារ, ឱ្យគិតប្រាក់ជំងឺចិត្តតាមមាត្រា៩១ (១៥ថ្ងៃក្នុង១ឆ្នាំទៅតាមអតីតភាពការងារ) និងសូមឱ្យគិតប្រាក់បន្ទាប់បន្សំ(ប្រាក់ទូរសព្ទប្រចាំខែ)។

ការទាមទារនេះ ក្រុមបុគ្គលិកកំពុងស្វែងរកមេធាវី និងខាងសហជីព ជាពិសេសមេធាវីស្ម័គ្រចិត្តជួយអន្តរាគមន៍ គោលបំណងគឺសូមទទួលអត្ថប្រយោជន៍ទៅតាមច្បាប់ការងារ។

អ្នកនាំសារ មិនទាន់អាចទាក់ទងខាងទូរទស្សន៍ CNC ដើម្បីសុំការបំភ្លឺបានទេក្នុងករណីនេះ៕

# អ្នកជំនាញឯករាជ្យ អ.ស.ប.ស្នើឲ្យឈប់ការប្រើប្រាស់តុលាការដើម្បីផ្តន្ទាទោសលើអ្នកហ៊ាននិយាយអំពីសិទ្ធិមនុស្ស

អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិបានរិះគន់ប្រទេសកម្ពុជាយ៉ាងខ្លាំងក្នុងការ ប្រើប្រាស់ប្រព័ន្ធតុលាការជាមធ្យោបាយក្នុងកាត់បន្ថយវិសាលភាពសម្រាប់សកម្មភាពរបស់ពលរដ្ឋ និងអំពាវនាវឲ្យប្រទេសកម្ពុជាការពារសេរីភាពបញ្ចេញមតិក្រោយពីអ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយសរុប ១៥ នាក់ក្នុងសំណុំរឿងពីរផ្សេងគ្នាត្រូវបានតុលាការផ្តន្ទាទោស។

អ្នកជំនាញឯករាជ្យបានលើកឡើងក្នុងសេចក្តីប្រកាសព័ត៌មានថាដោយបង្ហាញពីការព្រួយបារម្ភជាខ្លាំងអំពីសាលក្រមផ្តន្ទាទោសទាំងនេះ ដែលសរបញ្ជាក់ជាថ្មីម្តងទៀតនូវការធ្លាក់ចុះនៃលំហពលរដ្ឋ និងនយោបាយនៅកម្ពុជា ដែលមានលក្ខណៈជាប្រព័ន្ធនិងមានការរៀបចំច្បាស់លាស់។

អ្នកជំនាញឯករាជ្យបានបញ្ជាក់ថា ៖ «យើងខ្ញុំពិតជាភ្ញាក់ផ្អើលដែលថាតុលាការត្រូវបានប្រើប្រាស់ជាមធ្យោបាយជាថ្មីទៀតក្នុងបំបិទសំឡេងរិះគន់របស់អ្នកដែលហ៊ាននិយាយរិះគន់ រួមទាំងសកម្ម ភាពអហិង្សាដែលត្រូវបានការពារដោយសិទ្ធិសេរីភាពនៃការបញ្ចេញមតិ»។

ពីរឆ្នាំកន្លងទៅ អ្នកជំនាញឯករាជ្យទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានសរសេរលិខិតជារឿយៗជូនចំពោះរដ្ឋមន្ត្រីក្រសួងការបរទេស ដើម្បីលើកឡើងពីក្តីបារម្ភនានាអំពីការផ្តន្ទាទោសលើអ្នកធ្វើកិច្ចការអំពីសិទ្ធិមនុស្ស។

អ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិ បានអំពាវនាវដល់រាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវវិធានការបន្ទាន់ដើម្បីការពារលំហពលរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ តាមរយៈការអនុវត្តអនុសាសន៍នានា ដែលប្រទេសកម្ពុជាបានទទួលយកនៅពេលត្រួតពិនិត្យជាសកលតាមកាលកំណត់កាលពីឆ្នាំ២០១៩។ ក្នុងចំណោមអនុសាសន៍ទាំងនោះ ក៏មានការសន្យាថានឹងបង្កើតលក្ខខណ្ឌល្អប្រសើរដែលសង្គមស៊ីវិល រួមទាំងអ្នកការពារសិទ្ធិមនុស្ស អាចបំពេញការងាររបស់ខ្លួនដោយសេរី ដោយគ្មានការជ្រៀតជ្រែក ឬរាំង។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក ជិន ម៉ាលីន បានឆ្លើយតបទៅនឹងការលើកឡើងពីក្រុមអ្នកជំនាញឯករាជ្យសិទ្ធិមនុស្សរបស់ អ.ស.ប ពីសិទ្ធិមនុស្សនៅកម្ពុជាថាការលើកឡើងនេះមិនពិតនោះទេ ដោយសារជាគោលការណ៍សិទ្ធិមនុស្ស ការផ្តន្ទាទោសអ្នកប្រព្រឹត្តិបទល្មើសតាមនីតិវិធីតុលាការ និងផ្អែកតាមទិដ្ឋភាពច្បាប់គឺជាយន្តការនៃការលើកស្ទួយសិទ្ធិមនុស្ស និងនីតិរដ្ឋក្នុងសង្គមប្រជាធិបតេយ្យ។

លោក ជិន ម៉ាលីន បានលើកឡើងថា ៖ «សកម្មភាពនៃការប្រព្រឹត្តបទល្មើស ក៏មិនមែនជាការអនុវត្តសិទ្ធិសេរីភាពតាមបែបប្រជាធិបតេយ្យ ហើយក៏មិនត្រូវបានទទួលនូវការលើកទឹកចិត្តនិងការការពារដែរ។ ការអនុវត្តច្បាប់ដោយផ្អែកទៅលើទិដ្ឋភាពនីតិវិធីច្បាប់របស់កម្ពុជាតាមរយៈយន្តការរបស់តុលាការ គឺជាវិធានការច្បាប់ជាទូទៅ ដែលគេតែងតែប្រើប្រាស់នៅក្នុងសង្គមប្រជាធិបតេយ្យ នីតិរដ្ឋ»។

ក្រុមអ្នកជំនាញឯករាជ្យរបស់អង្គការសហប្រជាជាតិទាំង៣រូបនេះមាន លោក វិទិត មុនតាប៊ិន (Vitit Muntarbhorn) អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា, លោកស្រី អាយរីន ខាន់ (Irene Khan) អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិនៃសេរីភាពបញ្ចេញមតិ និងទស្សនៈ និងលោកស្រី ម៉ារី ឡល័រ (Mary Lawlor) អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពរបស់ក្រុមអ្នកការពារសិទ្ធិមនុស្ស៕

# កម្ពុជាជោគជ័យលើការបង្ហាត់សត្វសុនខ លើការហិតស្វែងរកមេរោគកូវីដ១៩





*អត្ថបទ៖ អមរិន្ទ ដានុត*

សត្វសុនខកម្ពុជាចំនួន១២ក្បាល នៃមជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា ហៅកាត់ថា ស៊ីម៉ាក់ (CMAC) បានទទួលជោគជ័យលើការហ្វឹកហាត់ ការហិតក្លិនស្វែងរកមេរោគកូវីដ១៩ ក្នុងដំណាក់កាលទី១បន្ទាប់ពីមានការហ្វឹកហ្វឺនអស់ជាច្រើនខែ។ សត្វសុនខទាំងនោះ គ្រោងនឹងដាក់ឱ្យប្រើប្រាស់ជាមួយមនុស្សផ្ទាល់ក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីមានការយល់ព្រមពីក្រសួងសុខាភិបាល។





ក្នុងពេលត្រួតពិនិត្យសត្វសុនខ ហិតក្លិន និងស្វែងរកមេរោគកូវីដ១៩ របស់អង្គភាព ស៊ីម៉ាក់(CMAC) កាលពីពេលថ្មីៗនេះ លោក ហេង រតនា អគ្គនាយកមជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា នៅមជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា ប្រចាំខេត្តកំពង់ឆ្នាំង ដែលជាទីតាំងសម្រាប់ហ្វឹកហ្វឺនសត្វសុនខ ហិតក្លិន និងស្វែងរកមេរោគកូវីដ១៩ បានឱ្យដឹងថា កាលហ្វឹកហ្វឺនសត្វសុនខអស់រយៈពេលបីខែមកនេះ គឺទទួលបានជោគជ័យយ៉ាងធំធេង សត្វសុនខទាំង១២ក្បាលអាច អាចធ្វើការហិតក្លិនដឹងនៃមេរោគកូវីដ១៩ បើទោះបីជាការហិតក្លិននេះទាំងបញ្ហាសខ្យល់ ឬបណ្ដោយខ្យល់យ៉ាងណាក៏ដោយនោះ។

អគ្គនាយក CMAC បន្តថា ៖«នៅពេលនេះយើងអាចនិយាយបានថា យើងរីករាយយើងពេញចិត្តចំពោះលទ្ធផលក្រោយការធ្វើការស្រាវជ្រាវរយៈពេល ប៉ុន្មានខែមកនេះហើយនិងការហ្វឹកហ្វឺននេះយើងឃើញថា សត្វសុនខរបស់យើងមានសមត្ថភាពពេញលេញ អាចរកអ្នកជំងឺមានផ្ទុកវីរ៉ុសកូវីដ១៩ ពិតប្រាកដមែន។ ឥលូវនេះសុនខមានសញ្ញាចេះរកឃើញហើយ ជាមួយនិងក្លិនអ្នកផ្ទុកវីរ៉ុសកូវីដ១៩ សំខាន់បំផុតការងារបន្ទាប់របស់យើងគឺការងារប្រតិបត្តិការ តើយើងត្រូវប្រើប្រាស់របៀបមិច ប៉ុន្តែអ្វីដែលយើងខិតខំស្រាវជ្រាវ ចង់ដឹងថា តើសុនខមានសមត្ថភាពអាចរកឃើញអ្នកផ្ទុកជំងឺ វីរ៉ុសកូវីដ១៩មែនដែរឬទេ?»។

លោក ហេង រតនា បានបញ្ជាក់ថា សត្វសុនខគឺជាឧបករណ៍មួយ ដ៏សំខាន់សម្រាប់ជួយដល់មន្ត្រីក្រសួងសុខាភិបាល ក្នុងការស្វែងរកអ្នកផ្ទុកមេរោគកូវីដ១៩ ដោយប្រើប្រាស់រយៈពេលខ្លី និងអាចទទួលលទ្ធផលច្រើន ជាពិសេសអាចប្រើប្រាស់ពួកគេនៅទីប្រជុំជន កន្លែងច្រកទ្វារអន្តរជាតិ និងកន្លែងហ្វូងមនុស្សរាប់ម៉ឺននាក់ដែលធ្វើការប្រមូលផ្តុំគ្នាជាដើមនោះ។ ប៉ុន្តែទោះជាយ៉ាងនេះក្តីការសម្រេចប្រើប្រាស់បែបណានោះគឺអាស្រ័យលើក្រសួងសុខាភិបាលជាអ្នកសម្រេចតែប៉ុណ្ណោះ។



លោក ហេង រតនា បន្តថា ៖«យើងឃើញថាប្រទេសមួយចំនួនក៏ប្រើប្រាស់សុខននេះសម្រាប់ប្រយុទ្ធប្រឆាំងនឹងមេរោគកូវីដ១៩ដែរ ភាគច្រើនគេប្រើសម្រាប់តំបន់ដែរមានមនុស្សច្រើន ដូចជាយុទ្ធសាស្រ្តរើសគ្រាប់គ្រួស ចេញពីអង្ករ រើសគ្រាប់ស្រូវចេញពីអង្ករ។ បើមនុស្សមានចំនួន១០០០នាក់ យើងយក Rapid Test ត្រូវតេស្ត១០០០នាក់ បើសុនខគឺមិនទេ គាត់ដើររក១០០០នាក់នោះ ថានរណាសង្ស័យ អ៊ីចឹងវាជាវិធានការមួយអាចយកទៅប្រើប្រាស់បាន។ ប៉ុន្តែបើចង់បានរបៀបនេះ អ្នកជំនាញបង្កើតស្តង់ដារប្រតិបត្តិការ ទៅតាមតម្រូវការ ឧទាហរណ៍ច្រកទ្វារព្រលានយន្តហោះ ច្រកទ្វារអន្តរជាតិ។ ល្បឿនរបស់សត្វសុនខអាចរកឃើញក្នុងរយៈពេល ១០ទៅ១៥នាទីទេ ក្នុងចំណោមមនុស្សច្រើន គាត់នឹងឱ្យសញ្ញាមកអ្នកជំនាញយើង»។

មន្ត្រីជំនាញមជ្ឈមណ្ឌលកម្ចាត់មីនកម្ពុជា (CMAC) បានសហការគ្នាជាមួយមន្ត្រីក្រសួងសុខាភិបាល ដោយបានធ្វើការហ្វឹកហាត់នូវសត្វសុនខចំនួន១២ក្បាលជាលើកដំបូង ឲ្យចេះស្វែងរក និងហិតក្លិនមេរោគកូវីដ១៩ ។ បន្ទាប់ពីធ្វើការហ្វឹកហាត់អស់រយៈពេលជាងបីខែមកនេះ សត្វសុនខទាំងនេះ មានលទ្ធភាពអាចស្វែងរកក្លិនវីរុស កូវីដ១៩ បានដោយជោគជ័យក្នុងដំណាក់កាលទី១នេះ ហើយនឹងអនុវត្តនូវដំណាក់កាលទី២ជាមួយនឹងមនុស្សផ្ទាល់នាពេលឆាប់ៗ ខាងមុខនេះផងដែរ៕

# តារាហូលីវូតសញ្ជាតិកម្ពុជាអាចនឹងមកផ្ទះលោកស្រីនៅសំឡូតឆ្នាំក្រោយ







*អត្ថបទ៖ អរិយបុត្រ*

លោកស្រី អេនជីលីណា ជូលី (Angelina Jolie) ដែលជាតារាសម្តែង ផលិតករភាពយន្ត សកម្មជនមនុស្សធម៌ បេសកជនពិសេសរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ហើយក៏ជាពលរដ្ឋកម្ពុជាមួយរូបផងដែរនោះ អាចនឹងត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំក្រោយ។

ការវិលត្រឡប់របស់លោកស្រី ក៏ត្រូវបានការិយាល័យនៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានបញ្ជាក់នៅលើបណ្តាញសង្គមរបស់ខ្លួនថ្មីៗនេះដោយបានអះអាងថា លោកស្រី នឹងត្រឡប់មកកម្ពុជាវិញនៅឆ្នាំក្រោយ ដើម្បីបង្កើតកម្មវិធីជួយស្ត្រីមួយ ដែលមានឈ្មោះថា «Women for Bees program» នៅស្រុកសំឡូត ខេត្តបាត់ដំបង។

ពាក់ព័ន្ធនឹងគម្រោងនេះ លោកស្រី អេនជីលីណា ជូលី បានប្រាប់ទស្សនាវដ្តីប្រចាំសប្តាហ៍របស់អាមេរិកថា លោកស្រីគ្រោងនឹងត្រឡប់មកកម្ពុជាវិញក្នុងពេលឆាប់ៗនេះ ដើម្បីបង្កើតកម្មវិធី ខាងលើនៅតំបន់សំឡូត ដែលលោកស្រីមានផ្ទះមួយនៅទីនោះ។

អ្នកស្រីបានប្រាប់ទស្សនាវដ្តីនោះថា៖ «យើងនឹងធ្វើការបន្ថែមទៀតជាមួយអង្គការយូណេស្កូ ដើម្បីស្វែងយល់ពីរបៀបពង្រីកនិងពង្រឹងការងារជួយស្ត្រី និងរបៀបដែលយើងកំពុងធ្វើការជាមួយប្រទេសកម្ពុជា និងកិច្ចការអភិរក្សជីវមណ្ឌលនានា»។

ទាក់ទិននឹងគម្រោងវិលត្រឡប់មកកម្ពុជាវិញ លោក សើ សាម៉េត អភិបាលស្រុកសំឡូត បានថ្លែង តាមទូរស័ព្ទថា វាជារឿងថ្មីមួយល្អសម្រាប់កម្ពុជា និងប្រជាជនក្នុងមូលដ្ឋាន។

លោកបានបញ្ជាក់ថា ៖ «ខ្ញុំមិនដឹងព័ត៌មាននេះទេ ប៉ុន្តែប្រសិនបើ លោកស្រី អេនជីលីណា ជូលី អាចត្រឡប់មកវិញ វានឹងល្អសម្រាប់ពួកយើង។ យើងរីករាយ និងមានមោទនភាពដែលបានស្វាគមន៍លោកស្រី ខណៈដែលលោកស្រីក៏មានផ្ទះផ្ទាល់ខ្លួននៅទីនេះដែរ»។

លោក សើ សាម៉េត បាននិយាយទៀតថា ផ្ទះរបស់លោកស្រីបានសាងសង់ជាច្រើនឆ្នាំមកហើយ ហើយលោកស្រី និងក្រុមគ្រួសារធ្លាប់សប្បាយរីករាយនៅទីនោះ។ ផ្ទះរបស់នាងស្ថិតក្នុងឃុំសំឡូត ជិតទឹកធ្លាក់មួយដែលមានទេសភាពស្អាតខ្លាំងណាស់។

អភិបាលស្រុកសំឡូតរូបនេះបានមានប្រសាសន៍ថា ៖ «តារាហូលីវូតរូបនេះ បានបន្តគាំទ្រដល់ការអភិរក្សធម្មជាតិ និងព្រៃឈើ ការអប់រំ ជាពិសេសសម្រាប់ក្មេងស្រី និងសុខុមាលភាពសង្គមផ្សេងទៀតនៅសំឡូតនេះយ៉ាងច្រើន»។

លោក សំ សុផាត អាយុ ៥៦ ឆ្នាំ រស់នៅទីក្រុងភ្នំពេញ បាននិយាយថា អេនជីលីណា ជូលី គឺជាតារាសម្តែងជនជាតិអាមេរិកដ៏ស្រស់ស្អាត និងជាសកម្មជនមនុស្សធម៌។ លោកស្រីមកកម្ពុជាច្រើនដងហើយក៏ជួយគម្រោងមួយចំនួននៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។

លោកបានបញ្ជាក់ថា៖ «ខ្ញុំស្គាល់គាត់ច្បាស់ ខ្ញុំក៏បានតាមដានរឿងរបស់នាងតាំងពីនាងមកថតរឿង Lara Croft: Tomb Raider ក្នុងឆ្នាំ ២០០០ បន្ទាប់មកគាត់មកលេងប្រទេសកម្ពុជាកាលពីប៉ុន្មានឆ្នាំមុន»។

លោកបានបន្តទៀតថា៖ «បើខ្ញុំមិនខុសទេ ហើយខ្ញុំចាំថា លោកស្រី ក៏មានសញ្ជាតិកម្ពុជាដែរ»។

មកដល់ពេលនេះក្នុងចំណោមកូនទាំង០៦ នាក់របស់លោកស្រី យុវជន ម៉ាដុក ជីវ៉ែន ជូលី ភីត (Maddox Chivan Jolie-Pitt) គឺជាក្មេងប្រុសជនជាតិខ្មែរម្នាក់ ដែលលោកស្រីបានជ្រើសរើសរូបគេយកទៅចិញ្ចឹមក្នុងទសវត្សរ៍ឆ្នាំ ២០០០ បន្ទាប់មកលោកស្រីក៏បានរកឃើញមូលនិធិមួយដើម្បីជួយដល់កម្មវិធីអភិរក្សនិងអភិវឌ្ឍន៍សហគមន៍នៅក្នុងតំបន់ការពារសំឡូត។

ក្រោយពីបានខិតខំរួមចំណែកជួយដល់ប្រទេសកម្ពុជា លោកស្រី អេនជីលីណា ជូលី បានទទួលសញ្ជាតិកម្ពុជាតាមព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រនរោត្តម សីហមុនី ក្នុងខែសីហាឆ្នាំ ២០០៥ ៕

# ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដាក់ឲ្យប្រើប្រាស់ StopCovid QR Vaccine




*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឱ្យដំណើរការប្រព័ន្ធ QR Code បណ្ណចាក់វ៉ាក់សាំងឌីជីថល StopCovid QR Vaccine ដោយតភ្ជាប់ប្រព័ន្ធ QR Code «ទប់ស្កាត់កូវីដStopcovid» ទៅនឹងប្រព័ន្ធទិន្នន័យចាក់វ៉ាក់សាំង នឹងដាក់ឱ្យប្រើប្រាស់ ចាប់ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១។

យោងតាម សេចក្តីជូនដំណឹង របស់ ក្រសួង ប្រៃសណីយ៍និង ទូរគមនាគមន៍ នៅ ថ្ងៃទី១៦ខែតុលាបានឱ្យដឹងថា ក្រសួង បានរៀបចំប្រព័ន្ធ QR Code បណ្ណចាក់វ៉ាក់សាំងឌីជីថលStopCovid QR Vaccine ដោយតភ្ជាប់ប្រព័ន្ធ QR Code ទប់ស្កាត់កូវីដStopcovid ទៅនឹងប្រព័ន្ធទិន្នន័យចាក់វ៉ាក់សាំង ដើម្បីដាក់ឱ្យប្រើប្រាស់ ចាប់ពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ នេះតទៅ។

ក្រសួងថា ប្រព័ន្ធ QR Code «StopCovid QR Vaccine» មានមុខងារសំខាន់ ចំនួនបីគឺ សម្រួលដល់ការស្រាវជ្រាវរកអ្នកពាក់ព័ន្ធនឹងជំងឺកូវីដ-១៩, គ្រប់គ្រងការធ្វើចត្តាឡីស័ក និងបង្ហាញព័ត៌មានអំពីការចាក់វ៉ាក់សាំងកូវីដ-១៩ របស់បុគ្គលម្នាក់ៗ។

ម្យ៉ាងទៀតប្រព័ន្ធនេះ នឹងចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈការកាត់បន្ថយការប៉ះពាល់ដោយផ្ទាល់ក្នុងការត្រួតពិនិត្យបណ្ណចាក់វ៉ាក់សាំង ដោយមិន ចាំបាច់យកបណ្ណចាក់វ៉ាក់សាំងតាមខ្លួនគ្រប់ពេលវេលា ឬព្រួយបារម្ភអំពីការបាត់បង់ ឬខូចខាតបណ្ណចាក់វ៉ាក់សាំងដោយប្រការណាមួយឡើយ ព្រមទាំងកាត់បន្ថយហានិភ័យនៃការក្លែងបន្លំទិន្នន័យលើបណ្ណចាក់វ៉ាក់សាំង។

ក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍ បាន បន្តថា ៖ «ប្រព័ន្ធនេះ អាចបង្ហាញពីព័ត៌មាននៃការចាក់វ៉ាក់សាំង រូបថត និងអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗ តាមរយៈការស្កេន QR Code នៅតាមច្រកចេញ-ចូលក្រសួង ស្ថាប័ន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន កន្លែងកំសាន្តអគារស្នាក់នៅរួម (ខុនដូ) ក្រុមហ៊ុន រោងចក្រ សហគ្រាសនានា»។

តាមរយៈការអនុវត្តគោលនយោបាយ ជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេសសម្រេចបានលទ្ធផលល្អប្រសើរ ក៏ដូចជាការត្រៀម លក្ខណៈសម្រាប់ការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ការបញ្ជាក់ពីការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅពេលចេញ-ចូលទីតាំងនានា គឺអាចការពារសុវត្ថិភាពទីកន្លែង បង្ការការចម្លង និងសម្រាលបន្ទុកលើការព្យាបាល របស់រាជរដ្ឋាភិបាល។

គួរបញ្ជាក់ថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានកិច្ចសហការជាមួយក្រុមការងារបច្ចេកទេសនៃគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស និងអនុគណៈកម្មការអន្តរក្រសួងប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលមានសមាសភាពអន្តរក្រសួង រួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសុខាភិបាល ក្រសួងយុត្តិធម៌និងរដ្ឋបាលរាជធានីភ្នំពេញ។

ជាមួយគ្នានេះដែរ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក៏បានណែនាំដល់ម្ចាស់ទីតាំងដែលមិនទាន់បានប្រើប្រាស់ប្រព័ន្ធ QR Code នេះ ត្រូវរួសរាន់បង្កើត QR Code សម្រាប់ទីតាំងរបស់ខ្លួនតាមរយៈគេហទំព័រ stopcovid.gov.kh។

ក្រសួងបាន បញ្ជាក់ថា ម្ចាស់ទីតាំងត្រូវតម្រូវឱ្យបុគ្គលដែលចេញ-ចូលទីតាំងរបស់ខ្លួន ស្កេន QR Code ដើម្បីបានដឹងពី ស្ថានភាពពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ របស់បុគ្គលទាំងនោះ តាមរយៈការបង្ហាញពណ៌លើអេក្រង់ទូរសព្ទក្រោយពេលស្កេន៕

# ជីវប្រវត្តិសង្ខេប និងស្នាព្រះហស្ថរបស់
# ព្រះយសបញ្ញា វី សុវិជ្ជា ជាថ្នាក់ដឹកនាំឆ្នើមវ័យក្មេង

*អត្ថបទ៖ ចារ សំសាវ៉ុន សន្តិបាលភិក្ខុ*

ព្រះយសបញ្ញា វី សុវិជ្ជា ព្រះរាជាគណៈថ្នាក់កិត្តិយស និងជាប្រធានសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង ជាបញ្ញវន្តសង្ឃខ្មែរវ័យក្មេងមួយព្រះអង្គ ដែលមានចំណេះដឹងខ្ពង់ខ្ពស់និងបានសាងស្នាព្រះហស្ថយ៉ាងច្រើនដើម្បីបុព្វហេតុ ជាតិ និងសាសនា។

មកស្គាល់ពីជីវប្រវត្តិសង្ខេប និងស្នាព្រះហស្ថរបស់ព្រះយសបញ្ញា វី សុវិជ្ជា ដូចតទៅ៖ ព្រះយសបញ្ញា វី សុវិជ្ជា ប្រសូតនៅឆ្នាំ១៩៧៩ នៅភូមិកូនខ្លុង ឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដោយមានបិតានាម ទិន សាវី មាតានាម សួង សល់ និងមានបងប្អូនបង្កើតចំនួន ៨នាក់ ប្រុស៥ ស្រី៣ ក្នុងនោះព្រះអង្គជាកូនទី។

ព្រះអង្គបានចូលទៅស្នាក់រៀនធម៌ និងបានសាងផ្នួសជាសាមណេរ នៅវត្តកូនខ្លុងជាវត្តស្រុកកំណើតក្នុងឆ្នាំ១៩៩៣ ។ ក្រោយសាងផ្នួសបានពីរព្រះវស្សា ព្រះអង្គបានចូលទៅសិក្សាធម្មវិន័យនៅវត្តកំពង់ព្រះ ក្រោយមកនិមន្តទៅបន្តការសិក្សាភាសាបាលីនៅពុទ្ធិកបឋមសិក្សាវត្តវេឡុវនារាម (ហៅវត្តឫស្សី) និងបានប្រឡងជាប់ចូលរៀននៅសាលាពុទ្ធិកអនុវិទ្យាល័យ អ៊ឹង ធួង។

ក្រោយសិក្សាបញ្ចប់នៅពុទ្ធិកអនុវិទ្យាល័យ អ៊ឹង ធួង ដោយពុំមានថ្នាក់សិក្សាបន្តព្រះអង្គបានធ្វើដំណើរទៅបន្តការសិក្សានៅឯទីក្រុងភ្នំពេញ។ នៅទីនោះព្រះអង្គបានបន្តការសិក្សារហូតបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិរយៈពេល៣ឆ្នាំ ថ្នាក់បរិញ្ញាបត្ររយៈពេល៤ឆ្នាំ បន្ទាប់មកបានប្រឡងជាប់ជាគ្រូបង្រៀនពុទ្ធិកវិទ្យាល័យ ដោយត្រឡប់មកបង្រៀននៅសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង។

ការចូលមកបង្រៀននៅសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង មិនមែនមានតួនាទីត្រឹមតែជាគ្រូបង្រៀនប៉ុណ្ណោះទេ ព្រះអង្គក៏ត្រូវបានថ្នាក់ដឹកនាំស្នើតែងតាំងជាប្រធានការិយាល័យថ្នាក់ឆ្នាំសិក្សាមូលដ្ឋានផងដែរ។ តាមរយៈអត្តចរិតល្អ មានភាពស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានសមត្ថភាពគ្រប់គ្រាន់ ក្រោយលោកគ្រូ ពុន ហង្សេន លាលែងតំណែងពីប្រធានសាខាទៅ ថ្នាក់ដឹកនាំសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង បានស្នើសុំថ្នាក់ដឹកនាំខាងលើ តែងតាំងព្រះយសបញ្ញា វី សុវិជ្ជា ជាប្រធានសាខាបន្តនៅឆ្នាំ២០១៧។

នៅពេលទទួលបានតំណែងជាប្រធានសាខាភ្លាម ព្រះយសបញ្ញា វី សុវិជ្ជា បានយកព្រះទ័យទុកពង្រឹងទៅលើប្រសិទ្ធភាពការងារ និងការសិក្សារបស់សមណនិស្សិត និស្សិតនៅក្នុងសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទាំងមូលភ្លាម។ ព្រះអង្គបានពង្រឹងប្រសិទ្ធភាពការងាររបស់បុគ្គលិកតាមរយៈ ការបណ្តុះបណ្តាលជំនាញបន្ថែម ការអនុវត្តបទបញ្ជាផ្ទៃក្នុង និងការលើកទឹកចិត្ត ធ្វើយ៉ាងណាឱ្យបុគ្គលិកគ្រប់រូបមានទឹកចិត្តបម្រើការងារ មានការទទួលខុសត្រូវ និងគោរពតួនាទីរបស់ខ្លួនឱ្យកាន់តែល្អប្រសើរឡើង។

ចំពោះការបណ្តុះបណ្តាលវិញ ព្រះអង្គបានផ្តោតទៅលើគ្រូបង្រៀនដែលមានចំណេះដឹងខ្ពស់ និងមានបទពិសោធន៍ច្រើន ក្រមសីលធម៌របស់សមណនិស្សិត-និស្សិតក្នុងសាលា និងពង្រឹងកម្មវិធីសិក្សាតាមរយៈការចង្អុលបង្ហាញរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជទីតាំងគោល ដោយស្របតាមអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

តាមរយៈការដឹកនាំរបស់ព្រះអង្គ សាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង មានគោលនយោបាយផ្តល់អាហារូបករណ៍បន្ថែមទៅលើអាហារូបករណ៍រដ្ឋ ដល់សមណនិស្សិត-និស្សិតដែលរៀនពូកែ និងជួយឧបត្ថម្ភនិស្សិតក្រីក្រដែលខ្វះលទ្ធភាព មានដូចជា ឧបត្ថម្ភអាហារកង់ និងផ្ទះស្នាក់នៅជាដើម (អន្តេវាសិកដ្ឋាន)។

មិនមែនតែចំពោះការបណ្តុះបណ្តាលកម្រិតពុទ្ធិកសាកលវិទ្យាល័យប៉ុណ្ណោះទេ ព្រះអង្គបានខិតខំស្វែងរកមូលនិធិមួយចំនួនផ្សេងទៀតជួយទៅដល់សមណសិស្សដែលសិក្សានៅកម្រិតពុទ្ធិកបឋមសិក្សា ពុទ្ធិកអនុវិទ្យាល័យ និងពុទ្ធិកវិទ្យាល័យផងដែរ។

ក្រៅពីការបណ្តុះបណ្តាលព្រះអង្គបានផ្តួចផ្តើមឱ្យមានកម្មវិធីមនុស្សធម៌ ជួយសង្គ្រោះពុទ្ធបរិស័ទជាប្រចាំ ដែលមួយរយៈចុងក្រោយមកនេះ សាលាបានជួយសង្គ្រោះពុទ្ធបរិស័ទនិងប្រជាជនទូទៅរាប់រយគ្រួសារ ដែលភាគច្រើនជាជនក្រីក្រ គ្រួសាររងគ្រោះដោយទឹកជំនន់ គ្រួសាររងគ្រោះដោយអគ្គីភ័យ គ្រួសារដែលរងផលប៉ះពាល់ពីវិបត្តិកូវីដ១៩ និងអ្នកជំងឺនៅតាមមន្ទីរពេទ្យជាដើម។ ថ្មីៗនេះ ព្រះអង្គបានសហការជាមួយសាលាអនុគណក្រុងបាត់ដំបង និងអង្គការពុទ្ធសាសនាដើម្បីការអប់រំនៃកម្ពុជា ដឹកនាំរៀបចំអាហារ និងសម្ភារៈប្រើប្រាស់មួយចំនួន ជូនអ្នកធ្វើចត្តាឡីស័កចំនួន៨០០អង្គ/នាក់ជាង។

ក្រៅពីជាប្រធានសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង ព្រះយសបញ្ញា វី សុវិជ្ជា ក៏ធ្វើការជាតំណាងអង្គការ Cambodian Village Fund នៅកម្ពុជា ផងដែរ។ អង្គការមួយនេះធ្វើការងារពាក់ព័ន្ធទៅនឹងវិស័យអប់រំ ពោលគឺជួយអភិវឌ្ឍសាលារៀនតាមរយៈការកសាងអគារសិក្សា រៀបចំទីធ្លាសាលា សាងបង្គន់ ធ្វើតារាងបាល់ទាត់ ពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងនិងជួយផ្តល់អាហារូបករណ៍ដល់សិស្សានុសិស្សក្រីក្រ នៅក្នុងឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង តាំងពីកម្រិតបឋមសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រ។

ព្រះយសបញ្ញា វី សុវិជ្ជា គឺជាសមាជិកសកម្មក្នុងកម្មវិធីដំណើរធម្មយាត្រារបស់សម្តេចព្រះមហា ឃោសនន្ទ ក្នុងនោះព្រះអង្គត្រូវបានលោកគ្រូ បប ម៉ាត ប្រគល់ថវិកាមួយចំនួនដើម្បីធ្វើសកម្មភាពផ្សេងៗតាមរយៈសាលាដូចជា ផ្តល់អាហារូបករណ៍ដល់សមណនិស្សិត និស្សិត និងធ្វើការងារមនុស្សធម៌ទូទៅ។

ដោយសកម្មភាពរបស់ព្រះអង្គមានភាពរស់រវើក ច្បាស់លាស់ និងត្រឹមត្រូវ ព្រះអង្គតែងទទួលបានការទុកចិត្តនិងផ្តល់ជាថវិកាសម្រាប់ការងារមនុស្សធម៌ពីសំណាក់សប្បុរសជនខ្មែរទាំងក្នុងស្រុកនិងក្រៅស្រុក ក្នុងនោះក៏មានអង្គការនិងសមាគមផងដែរ។

ព្រះយសបញ្ញា វី សុវិជ្ជា ជាព្រះសង្ឃបញ្ញវន្តវ័យក្មេងមួយព្រះអង្គនាយុគសម័យបច្ចុប្បន្នដែលមានចំណេះដឹងខ្ពង់ខ្ពស់ មានសមត្ថភាពគ្រប់គ្រាន់ និងមានស្នាព្រះហស្ថច្រើនជាអនេកទាំងក្នុងវិស័យពុទ្ធចក្រនិងអាណាចក្រ។ ព្រះអង្គធ្លាប់បានចូលរួមកម្មវិធីសិក្ខាសាលា កម្មវិធីប្រជុំសន្និសីទថ្នាក់ជាតិ និងអន្តរជាតិតូចធំទាំងឡាយ។ ព្រះអង្គប្រើប្រាស់ភាសាអង់គ្លេសបានល្អប្រសើរ និងអាចទំនាក់ទំនងការងារជាមួយបរទេសបានដោយឥតទើសទាក់។

តាមរយៈភាពប៉ិនប្រសប់និងពូកែទំនាក់ទំនង ព្រះយសបញ្ញា វី សុវិជ្ជា មានភាពស្និទ្ធស្នាល និងអាចធ្វើការបានយ៉ាងល្អក្នុងភាពជាដៃគូជាមួយអន្តរសាសនា ក្នុងនាមជាពុទ្ធសាសនិក ដើម្បីចូលរួមកសាងសុខដុមនីយកម្មសាសនានៅក្នុងសង្គមខ្មែរ។ ជារឿយៗសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង ដឹកនាំដោយព្រះអង្គផ្ទាល់តែងទទួលរៀបចំកម្មវិធីអន្តរសាសនាផ្សេងៗ ដើម្បីពង្រឹងទំនាក់ទំនងរវាងសាសនានិងសាសនា និងដើម្បីពិភាក្សាប្តូរយោបល់ស្តីពីរបៀបដោះស្រាយបញ្ហាវិបត្តិសង្គម។

ដោយមានចំណេះដឹងខ្ពង់ខ្ពស់ អត្តចរិតល្អ និងមានស្នាព្រះហស្ថច្រើនក្នុងវិស័យពុទ្ធចក្រនិងអាណាចក្រ ព្រះយសបញ្ញា វី សុវិជ្ជា តែងទទួលបានការកោតសរសើរ និងផ្តល់ជាប័ណ្ណសរសើរពីសំណាក់ថ្នាក់ដឹកនាំកំពូលៗ និងស្ថាប័ននានាជាច្រើន។ ថ្មីៗនេះ ព្រះយសបញ្ញា វី សុវិជ្ជា ទទួលបានការតែងតាំងជា ព្រះរាជាគណៈថ្នាក់កិត្តិយស ពីសំណាក់ សម្តេចព្រះសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា គណៈមហានិកាយ និងត្រូវបានអង្គការ Inner Trip REIYUKAI International បោះឆ្នោតប្រគេនឱ្យជាប់ជាថ្នាក់ដឹកនាំឆ្នើមវ័យក្មេងដែលមានទស្សនវិស័យវែងឆ្ងាយ ប្រចាំឆ្នាំ ២០២១ ដោយទទួលបានការឧបត្ថម្ភជាទឹកប្រាក់រង្វាន់ចំនួន ៥000 ដុល្លារអាមេរិក សម្រាប់ការងារមនុស្សធម៌។

ដោយភាពអំណត់អត់ធន់ និងការព្យាយាមតស៊ូប្រឹងប្រែងសិក្សារៀនសូត្ររហូតក្លាយជាបញ្ញវន្តសង្ឃមួយព្រះអង្គមានទាំងចំណេះដឹង និងគុណធម៌ ហើយបានលះបង់កម្លាំងកាយកម្លាំងព្រះទ័យធ្វើការងារបម្រើជាតិ និងសាសនា ព្រះយសបញ្ញា វី សុវិជ្ជា មិនត្រឹមតែជាមោទកភាពសម្រាប់ជាតិ និងសាសនាប៉ុណ្ណោះទេ តែក៏បានជាគំរូសម្រាប់ព្រះសង្ឃវ័យក្មេងជំនាន់ក្រោយ ក្នុងការអភិវឌ្ឍខ្លួនឱ្យក្លាយទៅជាបញ្ញវន្តសង្ឃដែលពោរពេញទៅដោយសមត្ថភាព និងគុណធម៌ ហើយអាចចូលរួមចំណែកអភិវឌ្ឍសង្គមជាតិ សង្គមសាសនាឱ្យរីកចម្រើនបានយ៉ាងល្អប្រសើរ ។

តំណាងពុទ្ធបរិស័ទទាំងឡាយ ខ្ញុំព្រះករុណាសូមសម្តែងនូវទឹកចិត្តសោមនស្ស និងដឹងគុណចំពោះព្រះវិរិយភាព គុណធម៌ និងការលះបង់ទាំងអស់នេះ។

សូមប្រគេនពរព្រះយសបញ្ញា វី សុវិជ្ជា ព្រះប្រធានសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជខេត្តបាត់ដំបង មានព្រះជន្មយឺនយូរ មានព្រះសុខភាពល្អ ទទួលបាននូវពុទ្ធពរទាំងឡាយបួន៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីបន្តភារកិច្ចការងារបម្រើជាតិ និងសាសនាតទៅមុខទៀត៕







# «យើងជាព្រះសហគមន៍ធ្វើដំណើរជាមួយគ្នា» ជាប្រធានបទនៃសន្និបាតគ្រីស្តបរិស័ទកាតូលិក ២០២១-២០២៣

*អត្ថបទ៖ ដាលីស*

សន្និបាតគ្រីស្តបរិស័ទកាតូលិក ២០២១-២០២៣ ត្រូវបានរៀបចំឡើងដោយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក្រោមប្រធានបទ «យើងជាព្រះសហគមន៍ធ្វើដំណើរជាមួយគ្នា» ក្រោមការដឹកនាំដោយលោកអភិបាលអូលីវីយេ ជ្មីតហាស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

សន្និបាតនេះ បានប្រព្រឹត្តទៅឡើងនាថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២១ ដោយមានការចូលរួមពីតំណាងព្រះសហគមន៍ តំណាងការិយាល័យព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងអង្គការការីតាសដែលជាតំណាងធម៌មេត្តាករុណារបស់ព្រះសហគមន៍ ប្រមាណជា៤០នាក់។

លោកអភិបាលអូលីវីយេ បានលើកឡើងក្នុងពេលប្រកាសបើកសន្និបាតនាពេលនោះថា ព្រះសហគមន៍ណែនាំឱ្យគ្រប់គ្នាពិចារណា គិតអំពីពន្លកថ្មីៗចូលរួមជាមួយធ្វើដំណើរជាមួយគ្នារួមគ្នាកសាងព្រះសហគមន៍ ដោយជាផ្លុងតែមួយចូលរួមប្រកាសដំណឹងល្អ។

លោកបានមានប្រសាសន៍ថា ៖ «នៅពេលយើងជាគ្រួសារតែមួយ យើងជួយគ្នាទៅវិញទៅមក និងព្រះសហគមន៍របស់យើងមានជីវិត។ យើងជាផ្លុងតែមួយ គឺយើងជាព្រះសហគមន៍ មិនមែនជាសហគមន៍ធម្មតា ប៉ុន្តែជាព្រះសហគមន៍របស់ព្រះជាម្ចាស់ យើងធ្វើដំណើរជាមួយគ្នា និងជានារ៉ាប់រងដោយមិនមានបែងចែកគណបក្ស ឬអ្នកមានអំណាច»។

នៅក្នុងពិធីបុណ្យអភិបូជាប្រកាសបើកអង្គសន្និបាតនេះដែរ លោកអភិបាលអូលីវីយេក៏បានលើកឡើងបន្ថែមថា ព្រះសហគមន៍កម្ពុជាមិនមែនជាព្រះសហគមន៍ឯកោនោះទេ គ្រប់គ្នាចូលរួមធ្វើដំណើរជាមួយព្រះសហគមន៍កម្ពុជា ឡាវ ព្រះសហគមន៍ក្នុងទ្វីបអាស៊ី និងព្រះសហគមន៍ទូទាំងពិភពលោក។

លោកអូលីវីយេ បានពន្យល់ថា ៖ «យើងធ្វើដំណើរជាមួយគ្នាដើម្បីប្រកាសដំណឹងល្អ ជាបេសកកម្មដែលយើងទទួលតាំងពីថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក ដោយយើងមានតួនាទីជាបូជាចារ្យ ជាព្រះមហាក្សត្រ និងជាព្យាការី ដែលបេសកកម្មក្នុងការអធិដ្ឋាន បម្រើ និងថ្លែងដំណឹងល្អរបស់ព្រះជាម្ចាស់ដើម្បីឱ្យមនុស្សស្តាប់ឮ»។

ព្រះសហគមន៍មិនមែនជាសហគមន៍មួយ ឬជាអង្គការមួយដែលគ្រាន់តែសម្តែងធម៌មេត្តាករុណាតែប៉ុណ្ណោះទេ ប៉ុន្តែព្រះសហគមន៍រស់នៅក្នុងព្រះយេស៊ូគ្រីស្ត ក្នុងព្រះជាម្ចាស់ដែលណែនាំឱ្យ ទទួលអំណោយដ៏សំខាន់បំផុតគឺជំនឿដែលផ្តល់ជីវិតអស់កលជានិច្ច។

លោកអូលីវីយេ មានបញ្ជាក់ថា ៖ «ខ្ញុំជឿថាពេលវេលាដែលយើងពិបាកជាពេលវេលាដែលយើងកំពុងធ្វើដំណើរជាមួយគ្នាដោយអធិដ្ឋានដើម្បីសូមទូលអង្វរព្រះបិតាប្រទានជំនឿដ៏រឹងមាំដែលយើងអាចធ្វើដំណើររួមជាមួយគ្នា និងរកឃើញអត្ថន័យនៃជីវិតរបស់យើង ដែលមើលឃើញនៅក្នុងគោលដៅនៃការប្រកាស




ដំណឹងល្អដើម្បីឱ្យមានសេចក្តីសង្ឃឹម ដើម្បីឱ្យជីវិតដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់បានទៅដល់គ្រប់ទីកន្លែង»។

នៅក្នុងឱកាសបើកអង្គសន្និបាតនេះ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញអូលីវីយេ បានប្រកាសអញ្ជើញព្រះសហគមន៍នីមួយៗ ស្ថាប័ន









នីមួយៗនៅក្នុងភូមិភាគភ្នំពេញ អង្គការព្រះសហគមន៍ បព្វជិត បព្វជីតា ដែលបម្រើការងារនៅក្នុងសង្គម នៅក្នុងរយៈពេល២ខែខាងមុខនេះ គិតជាមួយគ្នា តើធ្វើដូចម្តេចដើម្បីរួមរស់ធ្វើដំណើរជាមួយគ្នានិងប្រកាសដំណឹងល្អ?

លោកអភិបាលរូបនេះបានថ្លែងថា ៖ «យើងជាគ្រីស្តបរិស័ទគ្រប់វ័យ យើងជាលោកឪពុក ជាសមាជិកព្រះសហគមន៍ នៅព្រះសហគមន៍ជាអគ្គសញ្ញានៃព្រះគ្រីស្ត ដូចនេះយើងយល់ថាបេសកកម្មរបស់យើងធំអស្ចារ្យ។ យើងថែរក្សាជំនឿរបស់យើងយ៉ាងរឹងមាំ យកចិត្តទុកដាក់បង្ហាញធម៌មេត្តាករុណារបស់ព្រះអង្គគ្រប់ពេលវេលាដោយពោរពេញដោយសេចក្តីសង្ឃឹមជានិច្ច នៅក្នុងកម្ពុជា នៅទ្វីបអាស៊ី និងនៅក្នុងពិភពលោក ដោយដឹងថាព្រះយេស៊ូគ្រីស្តជាព្រះសិរសាដឹកនាំយើងអស់កល្បជានិច្ច»។

ប្រធានអង្គការការីតាសកម្ពុជា និងជាតំណាងអង្គការព្រះសហគមន៍កាតូលិកនានា លោក គឹម រតនា ក៏បានសម្តែងនូវអំណរសប្បាយនៅក្នុងព្រះសហគមន៍កាតូលិកនៅក្នុងកូវីដ-១៩នេះ។

លោកថា ៖ «យើងមានសកម្មភាពកាន់តែច្រើនឡើងច្រើនឡើង ធ្វើឱ្យយើងមានសកម្មភាពពេញបរិបូណ៌នៅក្នុងគ្រប់កាលៈទេសៈដែលបានកើតឡើង នឹងធ្វើឲ្យមនុស្សទូទៅបានទទួលព័ត៌មានកាន់តែច្រើន ហើយសកម្មភាពធម្មតាករុណារបស់ព្រះសហគមន៍យើងក៏មានច្រើនរួមទាំងសកម្មភាពជាមួយនិងសាសនាដទៃទៀតផងដែរ»៕

# សាលាដុនបូស្កូ លក់រុក្ខជាតិតាំងលំអររៃប្រាក់ជួយប្រទេសហៃទី

*អត្ថបទ៖ កក ស្រីនិ*

ក្នុងរយៈពេលជិតមួយខែមកនេះ សាលាដុនបូស្កូនៅកម្ពុជា ដែលគ្រប់គ្រងដោយក្រុមដូនជី បានប្រកាសដាក់លក់កូនរុក្ខជាតិផ្សាំជាច្រើន ដើម្បីយកប្រាក់ជួយដល់ជនរងគ្រោះដោយសារគ្រោះរញ្ជួយដីនៅប្រទេសហៃទី និងសាលាដុនបូស្កូ នៅក្នុងប្រទេសនោះ។

ប្រទេសហៃទីបានទទួលរងនូវគ្រោះរញ្ជួយដីចំនួន២លើក ដែលកើតមាននៅក្នុងឆ្នាំ២០១០ ក្នុងខែមករា មានកម្រិត៧រ៉ិចទ័រ និង២០២១ ក្នុងខែសីហាមានកម្រិត ៧,២ រ៉ិចទ័រ។ រញ្ជួយដីចុងក្រោយនេះ បានធ្វើឲ្យមនុស្សស្លាប់៣០៤នាក់ និងមានមនុស្សចំនួនជាង៦៥០.០០០នាក់ ត្រូវការជំនួយសង្គ្រោះបន្ទាន់ ក្នុងនោះរួមមាន កន្លែងស្នាក់នៅ ចំណីអាហារ និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនានាផងដែរ។

កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២១ គឺក្រោយមួយថ្ងៃនៃហេតុការអាក្រក់នេះ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បន្ទាប់ពីជ្រាបដំណឹងនេះ បានអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យគិតគូរជាបន្ទាន់ចំពោះគ្រោះមហន្តរាយមួយនេះ។







ដូនជី តាំង សុវណ្ណៈ ជានាយកសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូនៅទួលគោក បានឱ្យដឹងថា ដូនជីផ្ទាល់ជាមួយនឹងដូនជីផ្សេងទៀតចំនួន០៦នាក់ កំពុងតែដំណើរការនូវកម្មវិធីនេះ ដើម្បីជួយដល់សាលាដុនបូស្កូនៅប្រទេសហៃទី ដែលធ្លាប់រងគ្រោះដោយគ្រោះរញ្ជួយដី កាលពីឆ្នាំ២០១០ និងក្នុងអំឡុងខែសីហាកន្លងមកនេះផងដែរ។

ដូនជីសុវណ្ណៈ បានមានប្រសាសន៍ថា ៖ «ដើម្បីឆ្លើយតបទៅនិងសារលិខិតរបស់សម្តេចប៉ាប និងជួយដល់ជនរងគ្រោះនិងក្រុមដូនជីនៅប្រទេសហៃទី កម្មវិធីនេះក៏បានទទួលការចាប់អារម្មណ៍មិនត្រឹមតែជានិស្សិតនៅសាលាប៉ុណ្ណោះទេ ម្នងៗអតីតនិស្សិត អតីតគ្រូ និងមិត្តភក្តិដែលស្គាល់ ក៏បានចូលរួមជាមួយផងដែរ»។

កញ្ញា កាង យូរី ជាអតីតសិស្សចាស់នៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូទួលគោកបានឱ្យដឹងផងដែរថា ៖ «ខ្ញុំពិតជាមានការសប្បាយចិត្ត ដែលបានចូលរួមចំណែកក្នុងការជួយដល់សាលាដុនបូស្កូនៃប្រទេសហៃទី ដែលបានរងគ្រោះដោយសារតែគ្រោះរញ្ជួយដី បើទោះបីជាតិចតួចក្តី ដើម្បីជួយទៅដល់សាលានៃហៃទីក្តី ក៏សប្បាយចិត្តនៅក្នុងការជួយ»។

កញ្ញាបានបន្តថា មួយទៀតចំពោះការទិញកូនឈើ ក៏ជាផ្នែកមួយដើម្បីជួយដល់បរិស្ថាន មួយផ្នែកធំផង។

កញ្ញា យូរី បានបន្ថែមថា គាត់បានទិញជាច្រើនថូសម្រាប់ដាក់នៅកន្លែងធ្វើការ និងតាំងលំអរនៅក្នុងផ្ទះរបស់គាត់។ កញ្ញាបានបញ្ជាក់ រុក្ខជាតិទាំងនេះបនជួយច្រើនសម្រាប់សុខភាព និងបរិស្ថាន។

ទាក់ទងនឹងការរៃអង្គាសប្រាក់នេះ ដូនជីនាយកសាលាដុនបូស្កូនៅទួលគោករូបនេះ ក៏បានបញ្ជាក់ប្រាប់ អ្នកនាំសារ ថា ៖ «ចំណូលដែលទទួលបានពីការលក់តែម្តងវាមិនច្រើននោះទេ ប៉ុន្តែមានមិត្តភក្តិនិងអ្នកចាប់អារម្មណ៍ជាច្រើនបានចូលរួម ដោយអ្នកខ្លះបានបរិច្ចាគជាថវិកាថែមពីលើអ្វីដែលពួកគេបានជាវពីសាលា»។

ដូនជីសុវណ្ណៈ ឲ្យដឹងទៀតថា សម្រាប់ប្រភេទកូនឈើដែលមានលក់គឺមានតម្លៃចាប់ពី៣ដុល្លារឡើងទៅ រហូតដល់ ១៥ដុល្លារ ទៅតាមប្រភេទ កូនឈើ និងប្រភេទថូដែលអ្នកទិញចង់បាន។





ភាគច្រើននៃប្រភេទកូនឈើដែលលក់នេះ ជាប្រភេទប្រទាលដែលគេនិយមដាំនៅតាមផ្ទះ ឬដាក់នៅតុការិយាល័យធ្វើការ ហើយក៏ជាប្រភេទកូនឈើលំអរ។

ដូនជីបានបន្តថា ក្រៅពីគម្រោងលក់កូនឈើ ក៏មានកម្មវិធីលក់ស្បែកជើងឧបត្ថម្ភមួយ សម្រាប់យកកម្រៃជួយកិច្ចការនិងបេសកកម្មរបស់សាលាដុនបូស្កូផងដែរ។

ដូនជីសុវណ្ណៈបន្ថែមថា ៖ «កម្មវិធីនេះថ្វីត្បិតតែមិនបានបើកអ្វីឲ្យធំដុំមែន ប៉ុន្តែនៅតែមានអ្នកគាំទ្រ ហើយយើងក៏ណែនាំ អំពីស្បែកជើងនេះតាមអ្នកស្គាល់តៗគ្នា រហូតក៏ទទួលបានការគាំទ្រមួយភាគទៀតសម្រាប់កិច្ចការមនុស្សធម៌នៅប្រទេសហៃទី»។

ការរៃអង្គាសប្រាក់ដោយលក់កូនរុក្ខជាតិនិងលក់ស្បែកជើងនេះបានបញ្ចប់កាលពីខែតុលា ឆ្នាំ២០២១ដែលសរុបបានចំនួន១៣០០ដុល្លារអាមេរិក ត្រូវបានបញ្ជូនទៅកាន់សាលាដុនបូស្កូនៃប្រទេសហៃទី ដើម្បីចាត់ចែងកសាងសាលាបច្ចេកទេសនៅទីនោះឡើងវិញ រួមទាំងជួយដល់អ្នកខ្វះខាតនានារួចរាល់ហើយ។ ទោះជាយ៉ាងណា ដូនជីនាយកសាលាដដែលនេះ បានលើកឡើងដែរថា គម្រោងលក់កូនរុក្ខជាតិផ្សាំ នៅតែមានបើបងប្អូនមានចំណាប់អារម្មណ៍ អាចទំនាក់ទំនងទៅកាន់ខាងសាលាដុនបូស្កូទួលគោកបាន៕



# លោក ដាមីញាំង ហ្វានី ៖ «សន្តសន្តី ជា Idol សម្រាប់គ្រីស្តបរិស័ទ»

*អត្ថបទ៖ ដាលីស*

«គ្រីស្តបរិស័ទនីមួយៗត្រូវមាននរណាម្នាក់ជានិមិត្តរូបឬហៅថា Idol របស់ខ្លួន ដោយសារជីវិតរបស់សន្តបុគ្គលជួយណែនាំយើងឱ្យស្គាល់ និងឱ្យជួបជាមួយនឹងព្រះយេស៊ូដោយផ្ទាល់»។ នេះជាសម្ដីរបស់លោកបូជាចារ្យដាមីញាំង ហ្វានី អ្នកទទួលខុសត្រូវព្រះសហគមន៍មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង មានប្រសាសន៍ក្នុងថ្ងៃបុណ្យរំលឹកដល់សន្តបុគ្គលទាំងឡាយ កាលពីចុងខែតុលា នៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ក្នុងសង្កាត់បឹងទំពុន ខណ្ឌមានជ័យ។

លោកបូជាចារ្យដាមីញាំង មានប្រសាសន៍ថា ៖ «នៅក្នុងជីវិតរបស់យើងសព្វថ្ងៃមានមនុស្សមួយចំនួនដែលយើងហៅថា Idol ដែលមានឥទ្ធិពលនៅក្នុងជីវិតរបស់យើង ទាក់ទងទៅនឹងសោភណ្ឌ មិនថាមនុស្ស ឬសំណង់អគារនោះទេ»។

លោកបន្ថែមថា ៖ «ខ្ញុំគិតថាជីវិតរបស់យើងត្រូវតែមានសោភណ្ឌភាព ហើយនេះជាអ្វីដែលព្រះសហគមន៍គោរពគុណធម៌របស់សន្តបុគ្គល ដោយសារសន្តបុគ្គលជាតារាល្បី ជាIdol របស់គ្រីស្តបរិស័ទយើង»។

លោកបូជាចារ្យបានបញ្ជាក់ទៅកាន់គ្រីស្តបរិស័ទទាំងអស់ឱ្យចេះសម្លឹងមើលសោភណ្ឌភាពដែលជារបៀបរស់នៅនៃសន្តបុគ្គលដែលជាគំរូរបស់ខ្លួន ជាពិសេសគឺសម្លឹងមើលព្រះយេស៊ូដែលជាមហាសន្តបុគ្គលទាំងឡាយ។

តាមប្រពៃណីព្រះសហគមន៍កាតូលិក ជនដែលត្រូវបានប្រកាសតែងតាំងជាសន្តបុគ្គលត្រូវមានលក្ខណៈពិសេសដោយឆ្លងកាត់៣ដំណាក់កាលគឺ ត្រូវស្រាវជ្រាវអំពីជីវិតរបស់គាត់ ដែលបានរស់នៅស្របតាមព្រះបន្ទូលដំណឹងល្អ ក៏ដូចជាអំពីកេរ្តិ៍ឈ្មោះរបស់គាត់ ហើយត្រូវបានលោកអភិបាលតាមភូមិភាគ ប្រកាសថាជាអ្នកបម្រើរបស់ព្រះជាម្ចាស់។

ដំណាក់កាលបន្ទាប់គឺ ព្រះសហគមន៍ត្រូវប្រកាសអំពីការអស្ចារ្យមួយដែលបានកើតឡើង ដោយវិទ្យាសាស្ត្រមិនចេះពន្យល់ ហើយព្រះសហគមន៍ប្រកាសថាអ្នកមានសុភមង្គល និងដំណាក់ចុងក្រោយគឺត្រូវបានសម្ដេចប៉ាបប្រកាសជាសាធារណៈក្នុងនាមព្រះសហគមន៍ទាំងមូលបប្រកាសថាព្រះជាម្ចាសសព្វព្រះហឫទ័យនឹងបញ្ចូលឈ្មោះគាត់ក្នុងបញ្ជីធម៌អង្វរសន្តបុគ្គល។

លោកបូជាចារ្យ ដាមីញាំង ក៏បានប្រកាសស្នើដល់គ្រីស្តបរិស័ទទាំងអស់ បន្តការអធិដ្ឋានដល់ដំណើរការមរណសាក្សីនៅប្រទេសកម្ពុជាផងដែរ៕

# និស្សិតទេវវិទ្យាល័យម្នាក់ត្រូវតែងតាំងជាឧបដ្ឋាកឆាប់ៗនេះ

*អត្ថបទ៖ ដាលីស*



និស្សិតទេវវិទ្យាល័យម្នាក់ ត្រៀមតែងតាំងជាឧបដ្ឋាក គឺលោក ប្រាក់ ប៊ុនហុង ដែលនឹងរៀបចំនៅថ្ងៃទី៣០ វិច្ឆិកា ២០២១ ខាងមុខនេះ។ ពិធីតែងតាំងនេះនឹងធ្វើឡើងក្រោមអធិបតីភាព លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ផ្មិតហាស្លេរ រួមជាមួយលោកិអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម និងបាត់ដំបង ស្របតាមច្បាប់ និងប្រពៃណីព្រះសហគមន៍កាតូលិក ហើយនេះជំហានមួយមុននឹងទទួលតែងតាំងជាបូជាចារ្យ ដើម្បីបម្រើព្រះសហគន៍កាតូលិកនៅក្នុងភូមិភាគកំពង់ចាម។

លោកបូជាចារ្យ សិលា សួន ហង្សលី នាយកទេវវិទ្យាល័យកម្ពុជា សន្ត យ៉ូហាន ម៉ារីយ៉ាណេ បានលើកឡើងថា នៅឆ្នាំនេះបងប្រុសហុង នឹងទទួលការតែងតាំងជាឧបដ្ឋាក ដើម្បីត្រៀមខ្លួនទទួលអគ្គសញ្ញាជាបូជាចារ្យនៅឆ្នាំក្រោយ ទេវវិទ្យាល័យកម្ពុជាមានអំណរសប្បាយ ហើយនេះជាផលផ្លែដ៏ល្អពីទេវវិទ្យាល័យ។

លោកបូជាចារ្យ ហង្សលី បង្ហើបឱ្យដឹងអំពីរបៀបដើម្បីឈានទៅដល់ដំណាក់កាលតែងតាំងជាឧបដ្ឋាកគឺ បេក្ខជនត្រូវចូលទទួលការអប់រំតាមរយៈកាលកំណត់របស់ទេវវិទ្យាល័យចំនួន៧ឆ្នាំ ដោយត្រូវមានសរសរគោល៤។ លោកបូជាចារ្យបញ្ជាក់យ៉ាងនេះ «ទី១ ការអប់រំអំពីមនុស្សឱ្យមានសមត្ថភាពដោយអប់រំឱ្យនិស្សិតទេវវិទ្យាល័យបើកចិត្តគំនិតទទួលយកវប្បធម៌ផ្សេងៗ មានរបៀបរស់នៅរបស់មនុស្សឯទៀតៗ សម្របសម្រួលខ្លួនទាក់ទងជាមួយអ្នកផ្សេងៗមានភាពល្អប្រសើរ ចេះទទួលខុសត្រូវនៅលើកិច្ចការផ្សេងៗ និងមុខងារដែលត្រូវបំពេញ»។

លោកបានបន្តថា ទី២ ការអប់រំខាងផ្លូវវិញ្ញាណ គឺតាំងពីបេក្ខជនចូលទេវវិទ្យាល័យដំបូង និស្សិតត្រូវការទទួលបានការត្រាស់ហៅឱ្យរួមរស់ជាមួយព្រះជាម្ចាស់ជាព្រះត្រៃឯក គឺចូលទៅក្នុងទំនាក់ទមនងជិតស្និទ្ធនឹងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈការចូលរួមអភិបូជា អធិដ្ឋានផ្ទាល់ខ្លួននិងអធិដ្ឋានរួមជាមួយនិស្សិតឯទៀតៗ។

ចំណែកទី៣ អប់រំឱ្យបេក្ខជនមានចំណេះដឹងគឺរៀនពីមុខវិជ្ជាផ្សេងៗទាំងប្រវត្តិសាស្ត្រ ទស្សនវិជ្ជាក៏ដូចជាចំណេះដឹងទូទៅផ្សេងៗដើម្បីឱ្យបេក្ខជនបានស្គាល់និងចេះដឹង ហើយក៏មានបន្ថែមមុខវិទ្យា ទេវវិទ្យាដែលត្រូវរៀនរយៈពេល៤ឆ្នាំដើម្បីស្គាល់ពីព្រះជាម្ចាស់និងការបញ្ជូនបន្តប្រពៃណីព្រះសហគមន៍ ព្រមទាំងអំពីរបៀបរស់នៅតាមជំនឿផងដែរ។ និងទី៤ អប់រំឱ្យសិស្សិតទទួលស្គាល់ និងរៀនពីរបៀបថែរក្សាព្រះសហគមន៍ គឺមានការអនុវត្តផ្ទាល់ដោយរៀងរាល់ចុងសប្តាហ៍និស្សិតទៅតាមព្រះសហគមន៍ដម្បីជួយសកម្មភាពព្រះសហគមន៍ដោយរៀនពីរបៀបណែនាំពីលោកបូជាចារ្យដែលទទួលខុសត្រូវនៅទីនោះ។

លោកបូជាចារ្យ សិលា សួន ហង្សលី បានមានប្រសាសន៍ថា ៖ «ដោយឆ្លងកាត់សរសរទាំង៤នេះ ខ្ញុំយល់ឃើញថាបេក្ខជនមានសមត្ថភាពដើម្បីក្លាយទៅជាបូជាចារ្យនៅថ្ងៃអនាគត»។

លោកនាយកទេវវិទ្យាល័យបន្ថែមថា ក្រោយពីចប់ឆ្នាំទី៦នៅទេវវិទ្យាល័យ ត្រូវស្រាវជ្រាវព័ត៌មានផ្សេងៗពីបេក្ខជនតាមរយៈការឆ្លើយតបយោបល់ពីទីប្រឹក្សាទេវវិទ្យាល័យ ពីព្រះសហគមន៍ភូមិកំណើតបេក្ខជន និងព្រះសហគមន៍ដែលបងប្រុសបានទៅបម្រើ និងចុងក្រោយគឺការឆ្លើយតបពីលោកអភិបាលដើម្បីធ្វើសេចក្តីសម្រេច ទើបបេក្ខជនអាចសរសេរលិខិតស្នើសុំការតែងតាំង។

ពិធីតែងតាំងជាឧបដ្ឋាក ដល់និស្សិតទេវវិទ្យាល័យ ប្រាក់ ប៊ុនហុង នឹងធ្វើឡើងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ មុខងារជាឧបដ្ឋាកក្នុងព្រះសហគមន៍កាតូលិក គឺជាអ្នកបម្រើតុអាសនៈនៅក្នុងពិធីបុណ្យ ចែកព្រះកាយព្រះគ្រីស្ត ប្រារព្ធអគ្គសញ្ញាអាពាហ៍ពិពាហ៍ លាបប្រេងជូនអ្នកជំងឺ ធ្វើធម្មទេសនា អប់រំជំនឿ ធ្វើអគ្គសញ្ញាជ្រមុជទឹកជាដើម។

តាមការឱ្យដឹងពីបេក្ខជនដែលត្រៀមទទួលពិធីតែងតាំងជាឧបដ្ឋាក លោក ប្រាក់ ប៊ុនហុង មានប្រសាសន៍ថា ៖ «មុននឹងមកដល់ដំណាក់កាលនេះ ខ្ញុំបានត្រៀមខ្លួនជាយូរមកហើយតាំងពីខ្ញុំនៅទេវវិទ្យាល័យមកម្ល៉េះ គឺត្រូវត្រៀមខ្លួនដើម្បីបម្រើព្រះជាម្ចាស់ ត្រៀមរស់នៅក្នុងជីវិតនៅលីវ និងសម្របខ្លួននឹងរបៀបរស់នៅដោយស្តាប់បង្គាប់លោកអភិបាល និងអធិដ្ឋានជានិច្ច»។

លោក ប្រាក់ ប៊ុនហុង បានបន្ថែមថា ជីវិតនៃការត្រាស់ហៅជាបូជាចារ្យមានលក្ខណៈពិសេសដោយអាចណែនាំឱ្យបងប្អូនគ្រីស្តបរិស័ទចួបជាមួយព្រះយេស៊ូផ្ទាល់ ដោយយល់នេះជាការបូជាជីវិតសម្រាប់ព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍ លើសពីនេះទៅទៀតគឺការប្រកាសដំណឹងល្អដល់មនុស្សទាំងអស់ជាពិសេសចំពោះអ្នកក្រីក្រគ្មានទីពឹង។

និស្សិតទេវវិទ្យាល័យរូបនេះ បានស្នើឱ្យគ្រីស្តបរិស័ទបន្តការអធិដ្ឋានដល់រូបគាត់ ដើម្បីឱ្យគាត់មានកម្លាំងបម្រើព្រះសហគមន៍ និងបំពេញបេសកកម្មជាឧបដ្ឋាក។

បេក្ខជនឧបដ្ឋាកលោក ប្រាក់ ប៊ុនហុង មានដើមកំណើតជាខ្មែរភាគតិចព្នងនៅខេត្តមណ្ឌលគិរី ជាកូនទី៤ក្នុងគ្រួសារដែលមានឪពុកម្ដាយជាកសិករ ស្ថិតនៅឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរីក្នុងតំបន់ព្រះសហគមន៍ភូមិភាគកំពង់ចាម។

អនាគតឧបដ្ឋាករូបនេះ បានឱ្យដឹងថា មុននឹងចូលទេវវិទ្យាល័យ លោកបានតស៊ូនឹងជីវិត ដោយត្រូវរៀនសារឡើងវិញជាមួយកុមារនៅអង្គការភាពញញឹមនៃកុមារ ហាត់ការងារនៅខាងក្រៅដើម្បីចិញ្ចឹមជីវិត ហើយបានជម្នះឧបសគ្គទាំងឡាយដោយពឹងផ្អែកលើព្រះជាម្ចាស់ទាំងស្រុងរហូតមកដល់សព្វថ្ងៃនេះ៕

# គ្រូមត្តេយ្យសិក្សាព្រះសហគមន៍ ភូមិភាគកំពង់ចាម សិក្សាអំពី កុមារអូទីស្សឹមនិងរបៀបបង្រៀន





*អត្ថបទ៖ រឿន ស្រីម៉ាច*

គណៈកម្មការសហព័ន្ធគ្រូមត្តេយ្យភូមិភាគកំពង់ចាមបានរៀបកម្មវិធីសិក្ខាសម្រាប់អ្នកគ្រូមត្តេយ្យមួយក្រុមតូច និងតាមប្រព័ន្ធស្ស្រម(zoom) ក្រោមប្រធានបទ «ការផ្សព្វផ្សាយការអនុវត្តកម្មវិធីសិក្សាកុមារអូទីស្សឹម និងយុត្តិសាស្ត្រក្នុងការបង្រៀន» រយៈពេលពីរថ្ងៃចាប់ពីថ្ងៃ២១-២២ ខែកញ្ញា ឆ្នាំ២០២១ នៅព្រះវិហារកំពង់ចាមក្រុងស្ថិននៅក្នុងភូមិ១ សង្កាត់វាលវង់ ក្រុងកំពង់ចាម ក្រោមអធិបតីភាពលោកប្រ៊ុយណូ កូសម៌ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម។

បងស្រីក្លារ៉ាពេន ហ៊ីល ជាអ្នកសម្របសម្រួលកម្មវិធីសិក្ខាសាលានេះបានឲ្យដឹងថា៖«ដោយសារតែបញ្ហាជម្ងឺកូវីដ-១៩ ចឹងយើងមិនអាចជួបជុំគ្នាច្រើនបានទេគឺមានតែអ្នកគ្រូមួយចំនួនតូចគឺចំនួន៦នាក់តែប៉ុណ្ណោះ ហើយមួយចំនួនទៀតគឺយើងចូលរួមជាមួយគ្នាតាមរយៈប្រព័ន្ធZoom»។

បងស្រីបន្តថា៖ «មូលហេតុដែលលើកយកអំពីកុមារអូទីស្សឹម និងយុត្តិសាស្ត្រក្នុងការបង្រៀនជាគោលធំគឺព្រះសហគមន៍មានគោលបំណងចង់ស្វែងយល់អំពីស្ថានភាព និងអាការៈផ្សេងៗរបស់កុមារអូទីស្សឹម ដើម្បីងាយដឹងអំពីកុមារដែលមានបញ្ហានេះ(អូទីស្សឹម)ថាតើត្រូវជួយគេបានដោយរបៀបណាជាពិសេសកុមារនៅតាមជនបទ មិនសូវទទួលបានការមើលថែពីឪពុកម្តាយ»។

លើសពីនេះបងស្រីពេនហ៊ីលបន្ថែមថា៖ «ភាពជាអ្នកគ្រូមត្តេយ្យគឺត្រូវស្វែងយល់យ៉ាងច្បាស់អំពីជម្រៅចិត្ត និងវិធីសាស្ត្រក្នុងការបង្ហាត់បង្រៀនដល់កុមារតូចៗតាមកម្រិតរបស់គេ ហេតុនេះ ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមខិតខំយកចិត្តទុកដាក់ពង្រឹងប្រព័ន្ធអប់រំកុមារតាមមូលដ្ឋាន និងតាមសហគមន៍នានា ទៅលើគ្រូដើម្បីឲ្យមានកោរុកោសល្យច្បាស់លាស់ ជាពិសេសតាមកម្មវិធីសិក្សារបស់រដ្ឋជាដើម ដោយមានវគ្គសិក្ខាលាសានានាដោយមានការបង្ហាត់បង្រៀនផ្ទាល់ពីសំណាក់គ្រូមកពីក្រសួងអប់រំថ្នាក់ខេត្ត និងគ្រូដែលមានបទពិសោធន៍ និងឯកទេសច្បាស់លាស់មកពីបណ្តារាជធានី និងខេត្តមួយចំនួន។

កម្មវិធីសិក្ខាសាលាគ្រូមត្តេយ្យនេះគឺមានការចូលរួមចែករំលែកពីសំណាក់អ្នកស្រីភោគ ម៉ានី ទទួលខុសត្រូវសាលាអប់រំពិសេសសម្រាប់ការលូតលាស់(សម្រាប់កុមារអូទីស្សឹម)នៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ក្រុងភ្នំពេញ និងបងស្រីនៃសាលាមត្តេយ្យដុនបូស្កូទឹកថ្លា ក្រុងភ្នំពេញ និងសហការី ពន្យល់ណែនាំអំពីបច្ចេកទេសនៃការប្រៀន ការរៀបចំផែនការបង្រៀនរយៈពេលពេញមួយឆ្នាំ និងការអនុវត្តជាក់ស្តែងពេលបង្រៀន-ល-។

សព្វថ្ងៃព្រះសហគមន៍ភូមិភាគកំពង់ចាមមានមត្តេយ្យសិស្សាចំនួន១១កន្លែងរួមមាន៖

សាលាមត្តេយ្យអណ្តូងច្រុះ ក្តុលលើ ថ្មពេជ្រ ចម្លាក់ និងត្រពាំងកណ្តោល អ្នកលឿង ភូមិថ្មី

កោះរការ កអណ្តើក ព្រៃវែង ប៊ូស្រា និងសាលាមត្តេយ្យដាក់ដាំខេត្តមណ្ឌលគីរី៕

# ព្រះសហគមន៍ភូមិភាគកំពង់ចាមបួងសួងសន្តិភាពសម្រាប់ពិភពលោក





*អត្ថបទ៖ រឿន ស្រីម៉ាច*

ឆ្លៀតនៅក្នុងឱកាស «ទិវាសន្តិភាពអន្តរជាតិ ២១កញ្ញា» ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមបានរួមគ្នាអធិដ្ឋានដើម្បីសុំសុខសន្តិភាពសម្រាប់ទូទាំងសកលលោក។

ពិធីប្រព្រឹត្តទៅយ៉ាងឱឡារិកក្រោមអធិបតីភាពលោកប្រ៊ុយណូ កូសម៌ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម រួមជាមួយលោកបូជាចារ្យ បងប្រុស បងស្រី និងតំណាងគ្រីស្តបរិស័ទ មួយចំនួនតូច កាលពីថ្ងៃអង្គារ ទី២១ ខែកញ្ញា ឆ្នាំ២០២១ កន្លងទៅខាងមុខបរិវេណព្រះវិហារ សន្តហ្វ្រង់ស្វ័រ និងសន្តីក្លារ៉ាអាស៊ីស៊ី កោះរការក្រៅ។

លោកប្រ៊ុយណូ កូសម៌ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមបានឲ្យដឹងថា៖ «លោកពិតជាមានចិត្តត្រេកអរសប្បាយរួមជាមួយបងប្អូនគ្រីស្តបរិស័ទជិតឆ្ងាយមួយចំនួនតូច ក្នុងការអធិដ្ឋានរួមគ្នាក្នុងថ្ងៃទិវាសន្តិភាពអន្តរជាតិនេះទោះបីជាមិនមានគ្នាច្រើនព្រោះតែបញ្ហាជម្ងឺកូវីដក្តី តែព្រះសហគមន៍ឆ្លៀតធ្វើដោយគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល»។

លោកបន្ថែមថា៖ «ជាការពិតលោកផ្ទាល់ រួមទាំងព្រះសហគមន៍ក្នុងភូមិភាគទាំងមូលមិនធ្លាប់បានរៀបចំពិធីនេះក្តី តែវាជាឱកាសល្អ សម្រាប់ឲ្យយើងចេះបើកចិត្តដើម្បីអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ជាពិសេសឲ្យយើងនិកគិត ដល់អស់បងប្អូនដែលកំពុងរងទុក្ខវេទនាដោយភ្លើងសង្គ្រាម និងបញ្ហាជម្ងឺរាតត្បាតផ្សេងៗក្នុង សង្គម»។

លោកអភិបាលភូមិភាគកំពង់ចាមរូបនេះបានបន្តថា៖ «សូមឲ្យចេះយកចិត្តទុកដាក់ចំពោះគ្នានិងគ្នា សូមឲ្យថ្នាក់ដឹកនាំប្រទេសនានាបើកចិត្តទូលាយដើម្បីស្វែងរកសុខសន្តិភាពដល់ប្រជាជនខ្លួន ជាពិសេសសម្រាប់ទិវាសន្តិភាពនេះយើងសូមអង្វរនាងម៉ារីជាមាតាព្រះជាម្ចាស់ សម្រាប់សេចក្តីសុខសាន្តគ្រប់ទីកន្លែង ជាពិសេសសម្រាប់ស្ថានភាពជម្ងឺកូវីដ-១៩ នាពេលសព្វថ្ងៃ»។

ក្នុងអង្គពិធីរួមមាន៖ការពន្យល់អំពីអត្ថន័យទិវាសន្តិភាពពីលោកអភិបាលប្រ៊ុយណូ កូសម៌ អង្វរ សកល និងរបាំងបួងសួង ពិធីប្រោសទឹកព្រះពរ ពិធីលែងសត្វព្រាបសរជាសញ្ញា សន្តិភាព



ការបង្ហោះប៉េងប៉ោងរួមគ្នា និងអធិដ្ឋានរួមគ្នានៅខាងមុខរូបសំណាក់ព្រះនាងម៉ារី៕

# ព្រះសហគមន៍បឹងទំពុន គ្រោងនឹងបើកកម្មវិធីអប់រំជំនឿឡើងវិញ

*អត្ថបទ៖ សាខន ស៊ីម៉ូន*



ដោយសារការរីករាលដាលនៃវីរុសកូវីដ-១៩ ព្រះសហគមន៍នានាបានផ្អាកសកម្មភាព ក្នុងព្រះវិហារសូម្បីតែពិធីបុណ្យអភិបូជាប្រចាំថ្ងៃ និងប្រចាំថ្ងៃអាទិត្យ។ កម្មវិធីអប់រំជំនឿដែលធ្វើឡើងប្រចាំសប្តាហ៍ក៏ត្រូវផ្អាកមួយរយៈ ប៉ុន្តែក្នុងពេលថ្មីៗនេះ ព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ក្នុងរាជធានីភ្នំពេញ បានរៀបចំកិច្ចប្រជុំមួយ ដើម្បីបើកកម្មវិធីអប់រំជំនឿឡើងវិញ។

នៅក្នុងកិច្ចប្រជុំនេះដូនជី តេរេសា អេង សានី និងក្រុមគ្រូអប់រំជំនឿបានបង្ហាញនូវចំណាប់អារម្មណ៍ផ្សេងៗនៅក្នុងពេលដែលមានវិបត្តិកូវីដ-១៩ និងផលពិបាកនៅក្នុងការបង្រៀនសិស្សអប់រំជំនឿ។

នៅក្នុងពេលជាមួយគ្នានោះដែរ លោកបូជាចារ្យដាមីញ៉ាំង ហ្វារនី អ្នកទទួលខុសត្រូវព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន បានផ្តល់អនុសាសន៍អំពីការចែកក្រុមដើម្បីបង្រៀន ដោយផ្តោតទៅលើអគ្គសញ្ញាចំនួនពីរគឺអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាលាបថ្វាស។

សម្រាប់ក្រុមអប់រំជំនឿនេះ គឺចែកជាបួនក្រុមដូចឆ្នាំមុនៗដដែល មាន ក្រុមកុមារអាយុក្រោម១២ឆ្នាំ ក្រុមជំទង់ ពន្លកថ្មី និងអគ្គសញ្ញា។ ក្នុងអំឡុងពេលនេះ ព្រះសហគមន៍បានប្រកាសដល់អាណាព្យាបាលនិងឪពុកម្តាយកុមារ និងសិស្សដែលមានបំណងចង់បន្តរៀនអប់រំជំនឿ អាចមកជួបជាមួយលោកបូជាចារ្យឬដូនជី ដើម្បីចុះឈ្មោះចូលរៀនបាន។

ក្នុងថ្ងៃប្រជុំ កាលពីថ្ងៃទី៣០ ខែតុលា កន្លងមកនេះដែរ ក្រុមអ្នកទទួលអប់រំជំនឿ មិនទាន់សម្រេចបើកកម្មវិធីសិក្សាក្នុងថ្ងៃណានៅឡើយនោះទេ ដោយនឹងប្រជុំនៅពេលក្រោយទៀត ដើម្បីកំណត់ឲ្យបានច្បាស់លាស់ ដោយមានកំណត់ពីចំនួនសិស្ស ដើម្បីចែកជាក្រុមតាមថ្នាក់រៀននីមួយៗ។

លើសពីនេះលោកបូជាចារ្យដាមីញ៉ាំង រួមជាមួយដូនជីសានី បានថ្លែងអំណរគុណ និងលើកទឹកចិត្តដល់លោកគ្រូអ្នកគ្រូអប់រំជំនឿដែលបានស្ម័គ្រចិត្តបង្រៀន។ ដោយលោកបានស្នើឱ្យមានការចូលរួមរបស់បងប្អូនគ្រីស្តបរិស័ទនិងកូនសិស្សអប់រំជំនឿក្នុងការលើកទឹកចិត្តពួកគាត់ និងអនុវត្តវិធានការផ្សេងៗរបស់រាជរដ្ឋាភិបាល គឺ «៣កុំ ៣ការពារ» ជាពិសេសនៅក្នុងពេលអភិបូជាទាំងសិស្សអប់រំជំនឿ និងគ្រីស្តបរិស័ទត្រូវតែបំពេញលេខទំនាក់ទំនង និងឈ្មោះដើម្បីដឹងអំពីចំនួននិងអាស័យដ្ឋានទំនាក់ទំនង។ វិធីនេះ នឹងអនុវត្តសម្រាប់គ្រប់កម្មវិធីនៅក្នុងព្រះវិហារទាំងកម្មវិធីអប់រំជំនឿ អភិបូជា នៅក្នុងកម្មវិធីអាពាហ៍ពិពាហ៍ ក៏ដូចជាកម្មវិធីផ្សេងៗរបស់ព្រះ

# អ្នកនាង ង៉ែត សារ៉ូ៖ «កិច្ចការមនុស្សធម៌ធ្វើឲ្យជំនឿរឹងមាំនិងជិតស្និទ្ធជាមួយព្រះយេស៊ូ»

*អត្ថបទ៖ ឆាក លាំង*



«កិច្ចការមនុស្សធម៌ដែលខ្ញុំបានប្រព្រឹត្ត ធ្វើឲ្យជំនឿខ្ញុំរឹងមាំ និងកាន់តែជិតស្និទ្ធជាមួយព្រះយេស៊ូ» នេះជាការលើកឡើងរបស់អ្នកនាង ង៉ែត សារ៉ូ អាយុ ៣៣ឆ្នាំ ជាកូនចៅពុទ្ធបរិស័ទមួយគ្រួសារ ដែលមានបងប្អូនប្រុសស្រីចំនួន៧នាក់ រស់នៅក្នុងភូមិព្រៃជើង ឃុំគោគព្រិច ស្រុកគិរីវង្ស ខេត្តតាកែវ។

សព្វថ្ងៃ អ្នកនាង ង៉ែត សារ៉ូ មានជំនឿលើសាសនាគ្រីស្តនិកាយកាតូលិក ខុសពីបងប្អូននិងឪពុកម្តាយរបស់នាង។

អ្នកនាង ង៉ែត សារ៉ូ បានរៀបរាប់ថា អ្នកនាងបានស្គាល់ព្រះសហគមន៍កាតូលិកក្នុងឆ្នាំ២០០៧ តាមរយៈគ្រួសារគ្រីបរិស័ទ ក្រុមកាយឫទ្ធិ និងក្រុមសង្គហៈដែលបានធ្វើកិច្ចមនុស្សធម៌ក្នុងភូមិ។

គ្រីស្តបរិស័ទរូបនេះបានបន្តថា ៖ «ដំបូងឡើយខ្ញុំមិនមានគំនិតថាចូលព្រះសហគមន៍នោះទេ តែតាមរយៈការជួយដល់មនុស្សចាស់ជរា អ្នកគ្មានទីពឹង សកម្មភាពក្រុមកាយឫទ្ធិជួយបង្រៀនកូនក្មេងពីអនាម័យខ្លួនប្រាណ អំពីការគោរពចាស់ទុំក្នុងភូមិ និងបានឧបត្ថម្ភថវិកាដល់ក្មេងបានសិក្សាក្នុងសាលារដ្ឋ និងឯកជន ខ្ញុំមានក៏ចាប់អារម្មណ៍ចង់ចូល»។

ដោយឃើញពីកិច្ចការមនុស្សធម៌របស់ព្រះសហគមន៍នេះ សារ៉ូបានចូលឈ្វេងយល់ក្នុងអំឡុងចុងឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១១ ក៏ទទួលបានអគ្គសញ្ញាជ្រមុជទឹក នៅព្រះសហគមន៍ព្រះត្រៃឯកគិរីវង្ស ក្នុងមណ្ឌលសកម្មភាពតាកែវ។

អ្នកនាង ង៉ែត សារ៉ូ សព្វថ្ងៃរស់នៅជាមួយស្វាមី និងកូនប្រុសម្នាក់អាយុ២ឆ្នាំ និងកំពុងបំពេញការងារផ្នែកលេខាក្នុងព្រះសហគមន៍ព្រះត្រៃឯកគិរីវង្ស។ អ្នកនាងបានប្រាប់ទៀតថា មុននឹងក្លាយខ្លួនជាគ្រីស្តបរិស័ទនាងមានឧបសគ្គជាច្រើន ជាពិសេសពីសំណាក់ក្រុមគ្រួសារតែម្តង។

គ្រីស្តបរិស័ទរូបបានឲ្យដឹងថា ៖ «បងប្រុសរបស់ខ្ញុំហាមដាច់ខាតមិនឲ្យចូល បើខ្ញុំចូលព្រះសហគមន៍ គាត់នឹងសម្លាប់ខ្ញុំចោល ហើយម្តាយខ្ញុំវិញគាត់ថា អ្នកចូលសាសនាព្រះយេស៊ូគេមិនឲ្យគោរពឪពុកម្តាយ ពេលមានអ្នកស្លាប់គេមិនឲ្យធ្វើបុណ្យមិនយំ មិនឲ្យដុតធូបអីជាដើម...»។

អ្នកនាងបានបន្ថែមថា ៖ «ដោយការស្រឡាញ់ទោះជាបងប្រុសនិងម្តាយហាមខាតយ៉ាងណា ក៏ខ្ញុំនៅតែលួចទៅព្រះវិហាររាល់ថ្ងៃអាទិត្យ ដើម្បីចូលរួមអភិបូជា និងឈ្វេងយល់ជំនឿជាប្រចាំ តែមិនដែលបានសប្បាយចិត្តនោះទេ គឺមានតែភាពភ័យខ្លាច ព្រោះខ្លាចអ្នកផ្ទះមកឃើញ»។

អ្នកនាងថា ក្រោយទទួលការអប់រំ នាងព្យាយាមឲ្យក្រុមគ្រួសារស្គាល់ព្រះយេស៊ូតាមរយៈកិច្ចការរបស់នាងនិងអធិដ្ឋានទូលអង្វរទៅព្រះជាម្ចាស់សុំឲ្យព្រះអង្គជួយ បំភ្លឺផ្លូវ និងកែប្រែចិត្តពួកគាត់ឲ្យទទួលយកការសម្រេចចិត្តរបស់នាង។

រស់នៅក្នុងជីវភាពក្រីក្រ ពឹងលើរបរធ្វើស្រែ និងមានម្តាយស្រីមេម៉ាយ អ្នកនាង ង៉ែត សារ៉ូ បានប្រាប់ទៀតថា ដោយសារតែមានការជួយជ្រោមជ្រែងពីព្រះសហគមន៍ នាងបានបញ្ចប់ការសិក្សាផ្នែកលេខាធិកា នៅសាលាកាតូលិកមួយកន្លែងក្នុងទីក្រុងភ្នំពេញ។ ចាប់ពីពេលនោះមកក្រុមគ្រួសារក៏លែងហាមឃាត់ និងយល់ព្រមឲ្យរូបនាងប្តូរជំនឿបាន។

គ្រីស្តបរិស័ទរូបនេះ ប្រាប់អ្នកនាំសារ ថា នាងសប្បាយចិត្តដោយរស់នៅក្នុងជំនឿជាគ្រីស្តបរិស័ទ គឺរស់នៅដោយក្តីស្រឡាញ់ចំពោះបងប្អូន ជួយអ្នកខ្វះខាត អធិដ្ឋានសម្រាប់គេ សួរសុខទុក្ខ និងកសាងទំនាក់ទំនងល្អៗជាមួយបងប្អូនរួមជំនឿ និងអ្នកមានជំនឿផ្សេង។

អ្នកនាង ង៉ែត សារ៉ូ បានបន្ថែមថា ៖ «ទោះជួបរឿងអ្វីក៏ដោយ ខ្ញុំមិនដែលមានគំនិតថា បោះបង់ព្រះជាម្ចាស់នោះទេ ហើយរាល់កិច្ចការមនុស្សធម៌ រួមមានការសួរសុខទុក្ខអ្នកជំងឺ ជួយអ្នកក្រីក្រខ្វះខាត បានធ្វើឲ្យជំនឿរបស់ខ្ញុំកាន់តែរឹងមាំ ព្រោះថាវត្តមានបងប្អូន ជួយឲ្យខ្ញុំបានជួបនឹងព្រះយេស៊ូផ្ទាល់»។

អ្នកនាង ង៉ែត សារ៉ូ បានគូសបញ្ជាក់ថា ក្នុងថ្ងៃអនាគតនឹងនឹងរស់នៅដោយអនុវត្តតាមការប្រៀនប្រដៅរបស់ព្រះជាម្ចាស់ ដោយព្យាយាមបន្តជំនឿទៅអ្នកជំនាន់ក្រោយ តាមរយៈកិច្ចការដែលនាងបានធ្វើ និងជាគំរូល្អក្នុងនាមជាគ្រីស្តបរិស័ទ ដើម្បីឲ្យបងប្អូនបានយល់ពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅលើលោកនេះ៕

# *យើងជាគ្រួសារតែមួយ!*

ព្រះសហគមន៍កាតូលិករបស់យើងជាគ្រួសារដ៏ធំធេងមួយ នៅក្នុងទុក្ខលំបាកកូវីដ-១៩នេះ
យើងយកចិត្តទុកដាក់ជួយគ្នាទៅវិញទៅមក និងចែករំលែកសេចក្ដីស្រលាញ់ដល់បងប្អូនរបស់យើង។
ព្រះសហគមន៍ជួយដល់អ្នកត្រូវការអំឡុងពេលដែលយើងរួមគ្នាប្រយុទ្ធនឹងជំងឺកូវីដ-១៩។

## សកម្មភាពនានានៃព្រះសហគមន៍កាតូលិកកម្ពុជា

